# អំពី
# អក្សរខ្មែរ អក្ខរាវិរុទ្ធនៃភាសាខ្មែរ និង
# វចនានុក្រមខ្មែរ

ដោយឯ.ឧ.បណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់**
សាស្ត្រាចារ្យភាសាវិទ្យា
ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ
(ក.ជ.ភ.ខ.)

ខែកក្កដា ឆ្នាំ២០១២

*រក្សាសិទ្ធិ*

# <u>កាលាមសូត្រ</u>

កុំជឿលើអ្វី ដោយគ្រាន់តែអ្នកបានឮ
កុំជឿតាមពាក្យបរម្បរា ដោយសារតែ វាជាប្រពៃណីដែលគេ
ធ្លាប់ជឿរាប់តំណមកហើយ
កុំជឿលើអ្វី ដោយសារតែ មានគេនិយាយ និង ជាពាក្យចចាម
អារ៉ាមតៗគ្នា
កុំជឿលើអ្វី ដោយគ្រាន់តែឃើញថា មានសរសេរនៅក្នុងគម្ពីរ
សាសនារបស់អ្នក
កុំជឿលើអ្វី ដោយសារតែ វាជាពាក្យប្រៀនប្រដៅរបស់គ្រូអ្នក
និងចាស់ទុំរបស់អ្នក
ប៉ុន្តែ ក្រោយពេលបានសង្កេតនិងវិភាគល្អិតល្អន់ និង នៅពេល
ដែលអ្នកយល់ឃើញថា ធម៌ទាំងនោះវាសមស្របនឹង
វិចារណញ្ញាណ និង ដែលនាំមកនូវគុណប្រយោជន៍ចំពោះ
មនុស្សទូទៅហើយ ពេលនោះ សូមទទួលយកនិងជឿតាមចុះ ។

ព្រះសម្មាសម្ពុទ្ធ

ដកស្រង់ចេញពី **ពុទ្ធប្បវត្តិ ដោយរូបភាព**
និពន្ធដោយព្រះតេជគុណ **ទេវគោន សរណ មហាថេរា**
បោះពុម្ពឡើងវិញ នៅរោងពុម្ពមិត្តភាព កម្ពុជា-ជប៉ុន
ភ្នំពេញ ឧសភា ២០០១
ទំព័រឥតលេខ : ១៧ទំព័រមុនទំព័រទី១

# បុព្វកថា

ខ្ញុំបានរៀបរៀងសិក្សាកថានេះឡើង ដើម្បីរួមចំណែកក្នុងការបកស្រាយអក្ខរាវិរុទ្ធ និង ភាសាខ្មែរ។ ក្នុងឋានៈខ្ញុំជាប្រធាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.) ការសម្ងំនៅស្ងៀមស្ងាត់របស់ខ្ញុំ អាចនាំឲ្យសាធារណជនយល់ថា អ្វីៗដែលអ្នកនិពន្ធសៀវភៅឬវាគ្មិនបានផ្សព្វផ្សាយសុទ្ធតែត្រូវទាំងអស់។ តាមរយៈសិក្សាកថារបស់ខ្ញុំនេះ ខ្ញុំចង់បង្ហាញឲ្យឃើញថា វាមិនដូច្នោះទេ : អ្នកនិពន្ធឬវាគ្មិនខ្លះទិតៀនវចនានុក្រមសម្តេច **ជួន ណាត** ទាំងខុសទាំងត្រូវ។ ចំពោះអក្ខរាវិរុទ្ធនិងភាសាខ្មែរជាទូទៅវិញ អ្នកនិពន្ធនិងវាគ្មិនក៏បានត្រដាងការខ្វែងគំនិតគ្នាជាសាធារណៈដែរ(ខ្ញុំយល់ថា ចំណុចចម្រូងចម្រាសគប្បីផ្សព្វផ្សាយក្នុងមជ្ឈដ្ឋានអ្នកស្រាវជ្រាវសិន រង់ចាំការដោះស្រាយដោយ ក.ជ.ភ.ខ. បើពុំនោះសោតទេ វានឹងមានការបំពុលបរិយាកាសនាំឲ្យសាធារណជនវិលវល់ឬយល់ច្រឡំ)។

ក្រោយពីបានស្តាប់អ្នកបកស្រាយខ្លះ យូរៗទៅ ខ្ញុំមានអារម្មណ៍ថា ក្រុមប្រឹក្សាជាតិភាសាខ្មែរឥតបានធ្វើការអ្វីទេ ហើយ ភាសាខ្មែរកំពុងឋិតនៅក្នុងស្ថានភាពអាក្រក់ជាងពេលណាៗទាំងអស់។ តាមពិត ក.ជ.ភ.ខ.បានធ្វើការជាច្រើន ដោយសមាជិកចេះធ្វើសម្បទានចេះយោគយល់គ្នា។ បញ្ហាខ្វះឯកភាពក្នុងភាសាខ្មែរត្រូវបានដោះស្រាយមួយភាគធំ ហើយស្ថាប័ននេះកំពុងខំដោះស្រាយបញ្ហាដែលសេសសល់តទៅទៀត។

ចំពោះការផ្សព្វផ្សាយវិញ ក.ជ.ភ.ខ.បានប្រើគ្រប់មធ្យោបាយ : ចុះផ្សាយតាមព្រឹត្តិបត្រ ដែលបានចែកជូនគ្រប់មជ្ឈដ្ឋានសំខាន់ៗ, កិច្ចសហការជាមួយក្រសួងអប់រំ, សន្និសីទកាសែត, ការចុះផ្សាយតាមសារព័ត៌មាន, គេហទំព័រ។ល។

សិក្សាកថានេះ មានបំណងបំភ្លឺសាធារណជន បើមិនបានសព្វគ្រប់ ក៏អាចជួយ“បក់ផ្សែង”ដែលកំពុងគ្របដណ្តប់លើភាសាខ្មែរ ឱ្យរសាត់ចេញបានមួយភាគដែរ។

**ភ្នំពេញ ថ្ងៃសុក្រ ទី៦ ខែកក្កដា ឆ្នាំ២០១២**

បណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់**

សាស្ត្រាចារ្យភាសាវិទ្យា

ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

# <u>មាតិកា</u>

**<u>ចំណងជើង</u>** **<u>ទំព័រ</u>**


**បុព្វយោគ** .................................................................................................................... ១

I. **មូលហេតុដែលនាំឱ្យអក្សរខ្មែរមាន "ជើង"** ....................................................... ១

II. **ការគាំទ្រចំពោះវចនានុក្រមសម្តេច ជួន ណាត** ..................................................... ២

III- **បញ្ហាដែលចោទចំពោះវចនានុក្រមសម្តេច ជួន ណាត** ............................................. ៣

III.១.- បញ្ហាពិតប្រាកដ .................................................................................................. ៣

III.១.១- ការឆ្លាំងឆ្លាត់ឬការខ្វះចន្លោះដែលសម្តេច ជួន ណាត បានជ្រាបជាមុនថាវានឹងមាន ..................... ៣

III.១.២- បញ្ហាព្យាង្គតម្រួត ............................................................................................ ៣

III.២- បញ្ហាដែលគ្មានឬមិនត្រូវមានក្នុងវចនានុក្រម ........................................................ ៣

III.២.១- (ការ)លិខិនស្វរ ឬ ការសម្របស្វរ ........................................................................ ៣

III.២.២- ទិនាញស្វរ ........................................................................................................ ៥

IV. **ទស្សនៈសម្តេច ជួន ណាត ទាក់ទងនឹងការខ្វះចន្លោះដែលអាចមានក្នុងវចនានុក្រមរបស់ព្រះអង្គ** ..... ៦

V. **ទស្សនៈរបស់សម្តេច ជួន ណាត ទាក់ទងនឹងព្យាង្គតម្រួតនៃពាក្យកម្ចាយកើតចេញពីពាក្យដើមដែល សរសេរជាអក្សរតម្រួតច្នៃជើង** ................................................................................ ៧

VI. **អំពីព្យាង្គ** ............................................................................................................ ៨

VII. **សម្រង់កំហុសឬការភ្លាំងភ្លាត់ដែលមានក្នុងវចនានុក្រម សម្តេច ជួន ណាត** ........................ ១០

VII.១- សម្រង់ការឆ្លាំងឆ្លាត់មួយគ្រាន់តែជាឧទាហរណ៍ដែលបង្ហាញថា សម្តេច ជួន ណាត បានជ្រាប ច្បាស់ណាស់ថា វចនានុក្រម១.៩៦៨ទំព័រមិនអាចចៀសការឆ្លាំងឆ្លាត់ខ្លះៗបានទេ ........................ ១០

VII.២- ការឆ្លាំងឆ្លាត់ឬកំហុសស្រង់ដោយអ្នកនិពន្ធ"សំណេរនិងអក្ខរាវិរុទ្ធខ្មែរ" ......................................... ១១

VII.២.១- ការទិតៀនដោយតាន់ច្រឡំឬដោយយកការឆ្លាំងឆ្លាត់របស់សម្តេច ជួន ណាត ជាកំហុសដ៏ធ្ងន់ធ្ងរ .... ១១

VII.២.២- ការធ្វើឱតាសកម្មដោយផ្អែកលើការកាឡៃន័យនៃពាក្យ"ព្យាង្គតម្រួត" ឱ្យមានន័យខុសពី ន័យធម្មតា ........................................................................................................ ១២

VII.២.៣- សេចក្តីសន្និដ្ឋានលើទស្សនៈរបស់អ្នកនិពន្ធ"សំណេរនិងអក្ខរាវិរុទ្ធខ្មែរ" ..................................... ១៩

VIII. **សំណើរៀបចំកម្ទេចពាក្យតាមក្រុម ដើម្បីចៀសភាពរប៉ាត់រប៉ាយ** ...................................... ២០

VIII.១- ផ្នត់ (ឬ អព្ភាសបទ) .......................................................................................... ២១

VIII.១.១- រូបតាំដែក /-អម-/ & /-អ៊ម-/ និង កាឡូរូបរបស់វា
ដែលទាក់ទងនឹងព្យាង្គតម្រួតរបស់សម្ដេច ជួន ណាត ........................................ ២១
VIII.១.២- រូបតាំដែក /-អម-/ & /-អ៊ម-/ និង កាឡូរូបរបស់វា
សម្រាប់បង្កើតពាក្យសម្គាល់ឧបករណ៍ ........................................ ២១
VIII.១.៣- រូបតាំផ្នត់ដើម /អន-/ & /អ៊ន-/ និង កាឡូរូបរបស់វា
សម្រាប់បង្កើតពាក្យសម្គាល់ឧបករណ៍ ........................................ ២១
VIII.១.៤- រូបតាំផ្នត់ដើម /ក-/ & /គ-/ និង កាឡូរូបរបស់វា ដែលគេប្រើសម្រាប់បង្អាប់ ........................................ ២២
VIII.២- បឋមឫស ........................................ ២២
VIII.៣- ទ្វេនីយកម្មនៃព្យញ្ជនៈទី១នៃពាក្យណាមួយ ជាពិសេស កិរិយាសព្ទ ដើម្បីសម្គាល់អំពើផ្ទួន ........................................ ២៣
IX. **យោបល់សរុប** ........................................ ២៣
**គន្ថនិទ្ទេស** ........................................ ២៤

X X

X

# អំពី អក្សរខ្មែរ អក្ខរាវិរុទ្ធនៃភាសាខ្មែរ និង វចនានុក្រមខ្មែរ

រៀបរៀងក្រោមការទទួលខុសត្រូវសម្តេច **ជួន ណាត**[១]

**<u>ចុចូយោគ</u>**.- វចនានុក្រមជាក្បួន មិនមែនជាគម្ពីរសាសនាទេ។ សម្តេច **ជួន ណាត** មានព្រះបន្ទូលដ៏ប្រុងប្រយ័ត្នបំផុត។ ព្រះអង្គបើកឱ្យអ្នកប្រាជ្ញខ្មែរជំនាន់ក្រោយកែសម្រួលវចនានុក្រមនេះឱ្យកាន់តែប្រសើរឡើង (សូមអានចំណុចIV នៃសិក្សាកថានេះ)។ ប៉ុន្តែ បញ្ហាដែលចោទគឺព្រំដែនរវាងការកែសម្រួលនិងការកែបំផ្លាញ។

## I. <u>មូលហេតុដែលនាំឱ្យអក្សរខ្មែរមាន "ជើង"</u>

បើគេពិចារណា វរជនខ្មែរណាក៏អាចយល់បានដែរថា អក្សរខ្មែរមាន "ជើង" ពីព្រោះអក្សរនេះមានស្រះកប់[២], ឧ. ក្នុងអក្ខរាវិរុទ្ធនៃពាក្យ "កង" យើងពុំឃើញមាន<u>សញ្ញា</u>ស្រះទេ ទោះជាមួយព្យញ្ជនៈ "ក" ក្តី ឬ ជាមួយព្យញ្ជនៈ"ង"ក្តី ប៉ុន្តែ តាមទម្លាប់ យើងដឹងថា ក្នុងចំណោមព្យញ្ជនៈទាំងពីរនេះ ព្យញ្ជនៈទី១ ជាព្យញ្ជនៈបង្គោល ហើយ បុព្វបុរសយើងបានសន្មតថា មានស្រះ"អ"កប់ក្នុងនោះ រីឯព្យញ្ជនៈ "ង" វិញ វាជាព្យញ្ជនៈប្រកបឬត្តប្រកប ដែលគ្មានស្រះកប់ទេ។ បើផ្អែកលើ "Alphabet Phonétique International : (API) តាមភាសាបារាំង ឬ "International Phonetic Alphabet"(IPA) តាមភាសាអង់គ្លេស ហើយ ដែលយើងអាចហៅជាខ្មែរថា "អក្ខរក្រមសូរវិស័យអន្តរជាតិ" (អសអ) នោះ ស្រះកប់ត្រូវចេញជារូបមកក្រៅ ដែលភាសាវិទូគ្រប់សាសន៍អាចអានបានដែរថា [k<u>ɑː</u>ŋ]។ <u>ប្រសិនបើ</u>យើងអាចសន្មតបណ្តោះអាសន្នមួយពេល (ចាំបាច់ក្នុងនិទស្សន៍[៣])ថា ព្យញ្ជនៈខ្មែរឈប់មានស្រះកប់ ហើយ <u>ប្រសិនបើ</u>យើងអាចសុំសេចក្តីអនុញ្ញាតប្រើ "អ" ជាស្រះ (បណ្តោះអាសន្ន)នោះ យើងត្រូវសរសេរ "កអង" ទើបអាចអានថា [kɑːŋ] បាន ហើយ បើគេសរសេរ "កង" នោះ វាត្រូវនឹង "ព+ព ឬ កន្សោមព្យញ្ជនៈ"ទៅវិញទេ ដែលយើងអាចដាក់ជាអក្ខរក្រមសូរវិស័យអន្តរជាតិ (អសអ) ដូចនេះ ៖ [kŋ]។ ក្នុងសម្មតិកម្មនេះ គេឥតត្រូវការ "ជើង ្ង"ទេ (តាមសម្មតិកម្មនេះ ជើងអក្សរខ្មែរឯទៀតទាំងប៉ុន្មានក៏ឈប់មានប្រយោជន៍ដូចគ្នាដែរ[៤])។

ម្យ៉ាងទៀត គួរកត់សម្គាល់ថា នៅសម័យមុនអង្គរនិងសម័យអង្គរ គេដាក់វិរាម (អាន "វិរាមៈ") នៅលើតួ

---

[១]: ក្នុងសិក្សាកថារបស់ខ្ញុំមុនៗ ខ្ញុំមិនដែលដាក់តួនាទីរបស់ខ្ញុំក្នុងក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.) នៅលើក្របនៃស្នាដៃទាំងនោះទេ ប៉ុន្តែ សិក្សាលើកនេះជាសិក្សាកថាដែលខ្ញុំសរសេរឡើងដើម្បីនិយាយពីវចនានុក្រមសម្តេច **ជួន ណាត** ដែលគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) បានអនុម័តយកជាមូលដ្ឋាន [មុននឹងបានក្លាយទៅជាក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) ] : ដូច្នេះខ្ញុំសុំសេចក្តីអនុញ្ញាតដាក់តួនាទីខ្ញុំលើក្របនៃស្នាដៃនេះ។

[២]: ស្រះកប់ក្នុងអក្ខរាវិរុទ្ធនៃភាសាខ្មែរ មានចំនួនបួន ៖ "អ៉"ខ្លី [ɑ], "អ"វែង [ɑː], "អ៊"ខ្លី [ɔ] និង "អ៊" វែង [ɔː] ដោយមិននិយាយពីស្រះបីទៀតដែលត្រូវការការពន្យល់វែងបន្តិច (សូមអានសៀវភៅ "វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប" និពន្ធដោយអ្នកស្រាវជ្រាវមួយក្រុមក្រោមការទទួលខុសត្រូវរបស់បណ្ឌិត ព្រុំ ម៉ល់, ផ្សាយចេញនៅឆមាសទី១ ឆ្នាំ២០០៦, ទំព័រ៣៦ និង ៣៧)។

[៣]: ពាក្យ "និទស្សន៍" នេះត្រូវនឹងពាក្យបារាំង démonstration បានខ្ចីពីវចនានុក្រមបារាំង-ខ្មែរ តិប យក់ & ថាវ គន្ធ។

[៤]: អ្វីៗដែលខ្ញុំបានពណ៌នាខាងលើ វាគ្រាន់តែជាសម្មតិកម្មទេ ខ្ញុំគ្មានបំណងចង់ប៉ះពាល់ដល់កេរដំណែលរបស់បុព្វបុរសយើងឡើយ។

ប្រកបដើម្បីសម្គាល់ថា តួប្រកបនោះគ្មានស្រៈកប់ទេ, ឧ. ទូកិង, កុកិសក[៥], ...។ ដោយសារវិរាម គេអាចដឹងថា ក្នុងពាក្យ “ទូកិង” ព្យញ្ជនៈ“កិ” ជាតួប្រកប (ឥតមានស្រៈកប់) ហើយ គេត្រូវអានថា “ទូក-ង”។ ចំពោះពាក្យ “កុកិសក” គេត្រូវដឹងថា ព្យញ្ជនៈ“កិ”ជាតួប្រកប (ឥតមានស្រៈកប់) ហើយ អក្សរ “ស” និង “ក” សុទ្ធតែមិនមែនជាតួប្រកប ដូច្នេះ គេត្រូវអានថា “កុក-ស-ក”។

សម្មតិកម្មនេះមានភាពស្របនឹងភាពជាក់ស្តែងនៅក្នុងអក្សរថៃដែលមានស្រៈ [ɑ:] (សរសេរជាស្រៈថៃដូចនេះ ៖ “ะ”)។ គេគ្មានស្រៈកប់ទេ ដែលជាហេតុធ្វើឱ្យអក្សរគេឥតមានជើង ហើយ ក៏ឥតមានព្យាង្គតម្រួតដែរ។ ការពិពណ៌នាទាំងប៉ុន្មាន (ទាំងសម្មតិកម្ម ទាំងភាពជាក់ស្តែងក្នុងអក្សរថៃ) បង្ហាញឱ្យឃើញថា អក្ខរាវិរុទ្ធថៃមិនបាច់ខ្ចីព្យាង្គរាយពីអក្ខរាវិរុទ្ធខ្មែរទេ ពីព្រោះគេគ្មានស្រៈកប់និងគ្មានជើងព្យញ្ជនៈដើម្បីដាក់ខាងក្រោមតួព្យញ្ជនៈ (ព្យាង្គតម្រួតមិនអាចទៅរួចទេ ហើយ ព្យាង្គរាយជាច្រកតែមួយគត់សម្រាប់អក្ខរាវិរុទ្ធនៃភាសាថៃ)។

## II. ការគាំទ្រចំពោះវចនានុក្រមសម្តេច ជួន ណាត

កាលពីថ្ងៃពុធ ទី២០ ខែកុម្ភៈ ឆ្នាំ២០០៨ គណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) បានអនុម័តជាឯកច្ឆន្ទយកវចនានុក្រមសម្តេច **ជួន ណាត** ជាមូលដ្ឋាន ហើយ គួរកត់សម្គាល់ថា ទោះឥស្សរជនដែលបានរួមចំណែក (តិចក្តី ច្រើនក្តី) ក្នុងការកែប្រែអក្ខរាវិរុទ្ធក៏បានព្រមអនុម័តគាំទ្រដែរ ដោយលោកព្រមធ្វើសម្បទានដើម្បីឱ្យការសរសេរពាក្យខ្មែរមានការឯកភាព (គួរសរសើរឥស្សរជនទាំងនោះណាស់)។

ខ្ញុំសូមរំលឹកថា នៅក្នុងសន្និសីទរៀបចំដោយវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជាជាច្រើនលើក អ្នកដែលបានទាមទារឱ្យគេសរសេរពាក្យឱ្យស្របតាមអក្ខរាវិរុទ្ធ ដែលមានក្នុងវចនានុក្រមសម្តេច **ជួន ណាត** សុទ្ធសឹងជាខ្មែរក្នុងស្រុក (មាន “អាណិកជនខ្មែរ”[៦] វិលមកពីបរទេសមកនៅស្រុកខ្មែរវិញតិចតួចណាស់)។

ម៉្យាងទៀត សូមសាធារណជនជ្រាបថា ឥស្សរជនកំពូលៗដែលគាំទ្រវចនានុក្រមសម្តេច **ជួន ណាត** ដូចសម្តេចបណ្ឌិតសភាចារ្យ អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, ឯកឧត្តម **អ៊ុំ សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ និង ឥស្សរជនផ្សេងៗទៀត ទោះនៅក្រសួងអប់រំក្តី ឬ នៅក្រសួងឬស្ថាប័នផ្សេងទៀត

---

[៥]: ខ្ញុំមិនស្រង់ឧទាហរណ៍ពីភាសាខ្មែរបុរាណ ហើយ បែរជាយកឧទាហរណ៍ក្នុងភាសាខ្មែរបច្ចុប្បន្នវិញនេះ ពីព្រោះខ្ញុំចង់ឱ្យវាងាយយល់ ដោយសារយើងស្គាល់ពាក្យទាំងនេះ។

[៦]: ខ្ញុំដាក់អព្តន្តរនៅខាងឆ្វេងនិងខាងស្តាំនៃពាក្យ“អាណិកជន” ពីព្រោះខ្ញុំប្រើវាតាមគេប្រើនៅប្រទេសខ្មែរដើម្បីសម្គាល់ខ្មែរណាដែលរស់នៅបរទេស ហើយមកលេងប្រទេសខ្មែរ។ ការប្រើបែបនេះប្រាសចាកន័យដើមរបស់ពាក្យដែលគណៈកម្មការវប្បធម៌បានបង្កើតមកដើម្បីសងពាក្យបារាំង ressortissant ដែលសម្គាល់ជនបរទេសនៅក្នុងប្រទេសណាមួយដែលមិនមែនជាប្រទេសខ្លួន ដូច បារាំង ចិន ថៃ ជាដើម ដែលឥតមានសញ្ជាតិខ្មែរ ប៉ុន្តែ រស់នៅក្នុងប្រទេសខ្មែរ ហើយ ដែលត្រូវបានស្ថានទូតរបស់គេជួយថែរក្សាការពារផងដែរ ក្រៅពីកាតព្វកិច្ចដែលជនទាំងនោះត្រូវគោរពច្បាប់នៃប្រទេសខ្មែរ។ ខ្មែរដែលមានសញ្ជាតិអាមេរិកាំង ហើយ ដែលមកលេងប្រទេសខ្មែរជាទេសចរ មិនមែនជាអាណិកជនសម្រាប់ប្រទេសខ្មែរនេះទេ (លើកលែងតែបើគេមករស់នៅប្រទេសខ្មែរជាស្ថាពរ ឬ រយៈពេលយូរ ដោយឥតមានសញ្ជាតិខ្មែរ)។

ក្តី មិនមែនជា "អាណិកជនខ្មែរ" ដែលត្រឡប់ពីបរទេសមកនៅប្រទេសខ្មែរវិញទេ ទោះបីមានជនជំពូកនេះខ្លះដែរក៏ដោយ។

## III- បញ្ហាដែលទាក់ទងវចនានុក្រមសម្តេច ជួន ណាត

### III.១- បញ្ហាពិតប្រាកដ

#### III.១.១- ការខ្លាំងខ្លាត់ឬការខ្វះចន្លោះដែលសម្តេច ជួន ណាត បានជ្រាបជាមុនថានឹងមាន

ចំពោះបញ្ហានេះ ខ្ញុំគ្រាន់តែបោះតម្រុយដើម្បីនាំស្មារតីសាធារណជនឆ្ពោះទៅមុខ ហើយ ចំពោះបញ្ហាណាដែលគប្បីអត្ថាធិប្បាយភ្លាមៗ ខ្ញុំក៏អត្ថាធិប្បាយទៅ។ ចំពោះបញ្ហាណាដែលត្រូវបញ្ជូនទៅចំណុចខាងក្រោយ ខ្ញុំក៏ធ្វើយ៉ាងនេះទៅ។

ចំពោះបញ្ហាដែលមានក្នុងចំណុច II.១.១- សូមសាធារណជនអានចំណុច IV ខាងក្រោយ ដែលមានការពន្យល់សព្វគ្រប់ល្មមយល់បានហើយ។

#### III.១.២- បញ្ហាព្យាង្គតម្រួត

ត្រង់ចំណុចនេះដែលសម្តេចព្រះសង្ឃរាជ **ជួន ណាត** បាន "ទុកឱកាសឲ្យប្រើតាមទម្លាប់ដែលសរសេរថ្មីកដែរទៅហើយនោះ ខ្លះទៅសិនចុះ" យើងបានសង្កេតឃើញថា "ខ្លះទៅសិនចុះ"នេះ បានកន្លងមក៤៥ឆ្នាំហើយ ហើយអាចបន្តទៅទៀត ពីព្រោះអ្នកស្រឡាញ់ព្យាង្គរាយខ្លះបានខំការពារព្យាង្គនេះយ៉ាងស្វិតស្វាញ (សូមសាធារណជនអានចំណុច V)។

### III.២- បញ្ហាដែលគ្មានឬមិនត្រូវមានក្នុងវចនានុក្រម

#### III.២.១- (ការ)លំឱនសួរ ឬ ការសម្របសួរ

**កំណត់ចំណាំ** : - ពាក្យ"សម្របសួរ"មានន័យសមស្របជាង ប៉ុន្តែ គេនិយមប្រើពាក្យ "លំឱនសួរ"។

អ្នកស្រាវជ្រាវខ្មែរមួយចំនួនបានយកព្យញ្ជនៈនៃមូលភេទ "អ" និង ព្យញ្ជនៈនៃមូលភេទ "អ៊ី" ទៅរៀបជាតារាង ដោយបន្ថែមព្យញ្ជនៈដែលកើតពីវណ្ណយុត្តិ (មូសិកទន្តនិងត្រីសព្ទ)ផង ដូចមានខាងក្រោម ៖

| មូលភេទ អ | | មូលភេទ អ៊ី |
|---|---|---|
| ក, ខ, ង៉ | ............ | គ, ឃ, ង |
| ច, ឆ, ញ៉ | ........... | ជ, ឈ, ញ |
| ដ, ឋ | ........... | ឌ, ឍ |
| ត, ថ, ណ | .......... | ទ, ធ, ន |
| ប៉, ផ, ម៉ | ........... | ព, ភ, ម |
| ប | ........... | ប៊ |

យ៉, រ៉, ឡ .......... យ, រ, ល

វ៉, ស, ហ .......... វ, ស៊, ហ៊

អ .......... អ៊។

អ្នកស្រាវជ្រាវទាំងនោះបានសន្និដ្ឋានថា ដើម្បីកត់ត្រាសូរព្យញ្ជនៈខ្មែរ យើងត្រូវការមិនត្រឹមតែសញ្ញាព្យញ្ជនៈ ៣៣តួទេ ប៉ុន្តែ ត្រូវការរហូតដល់៤៤តួឯណោះ។ នៅពេលនោះ គេមិនទាន់ស្គាល់ពាក្យ “ទំនាញសូរ” ទេ គេនិយមប្រើពាក្យ “(ការ)លំឱនសូរ”។ “(ការ)លំឱនសូរ”នោះ ទាក់ទងនឹងព្យញ្ជនៈដែលកើតពីវណ្ណយុត្តិ គឺ ង៉, ញ៉, ប៉, ម៉, ប៊, យ៉, រ៉, វ៉, ស៊, ហ៊, អ៊។

ដើម្បីចៀសការប្រើមូសិកទន្តនិងត្រីសព្ទច្រើនសន្ធឹកសន្ធាប់ បុព្វបុរសខ្មែរបានប្រើ“(ការ)លំឱនសូរ” ដូចមានឧទាហរណ៍មួយចំនួន ខាងក្រោម ៖

*ច្រងេងច្រងាង, ប្រញាប់, ក្រមា, សំយាប, កម្រ, ស្រវា, ទាហាន, ...។*

ពាក្យដែលសរសេរតាមការលំឱនសូរដែលមានក្នុងវចនានុក្រមសម្ដេច **ជួន ណាត** មិនដែលអ្នកណាកែប្រែទេ ហើយ ក៏គ្មានអ្នកណាមានបំណងនឹងបដិសេធចោលដែរ ប៉ុន្តែ បើគេហៅបាតុភូតនេះថាជា “ទំនាញសូរ” ដោយសង្កត់ធ្ងន់ថា មិនត្រូវបដិសេធទេនោះ សម្ដីបែបនេះនាំឱ្យ ៖

(១)-សាធារណជនយល់ច្រឡំថា មានជនណាម្នាក់ឬក្រុមណាមួយមានបំណងចង់បដិសេធអក្ខរាវិរុទ្ធនៃពាក្យ *កម្រ, ក្រមា, ទាហាន ។ល។* ការយល់បែបនេះ ជាការយល់ច្រឡំ។

(២)- សាធារណជនយល់ច្រឡំថា លោកបណ្ឌិតសាស្ត្រាចារ្យ ច័ន្ទ សំណព្វ ការពារ (ដោយប្រយោល) ពាក្យដែលក្នុងនោះចលនា“ទំនាញសូរពិតប្រាកដ” (កើតនៅរវាងឆ្នាំ១៩៧១)ជំនួសជាទូទៅព្យញ្ជនៈ “ណ”និង“ឡ”ដោយព្យញ្ជនៈ“ន”និង“ល”។ ការជំនួសជាទូទៅព្យញ្ជនៈ“ណ”និង“ឡ”ដោយព្យញ្ជនៈ “ន”និង“ល” ដែលកែប្រែអក្ខរាវិរុទ្ធភាសាខ្មែរដែលមានក្នុងវចនានុក្រមសម្ដេច **ជួន ណាត** នោះ គណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) បានអនុម័តឱ្យឈប់ប្រើហើយ ៖ សូមសាធារណជនជ្រាប (សូមមេត្តាអានចំណុច II)[៧]។

<u>**កំណត់ចំណាំ**</u> :

១- (ការ)លំឱនសូរឥតត្រូវបានធ្វើជាទូទៅទេ។ យើងអាចស្រង់ពាក្យជាច្រើន ដែលបុព្វបុរសយើងបានប្រើមូសិកទន្តឬត្រីសព្ទ(ឬសញ្ញាជំនួស), ឧទាហរណ៍ ៖ សាំញ៉ាំ, អាម៉ាស់, រអ៊ូ, រអ៊ូរទាំ, ...។

២- ក្នុងភាសាបារាំង មានបាតុភូតប្រហាក់ប្រហែលនឹង“(ការ)លំឱនសូរ”របស់យើងនេះដែរ ដែលគេហៅថា "**assimilation**" ហើយ បើយើងប្រែថា "ការសម្របសូរ" ប្រហែលជាសមស្របជាង, ឧទាហរណ៍ ៖

---

[៧] : ក្នុងសៀវភៅគាត់ដែលមានចំណងជើងថា “សំណេរនិងអក្ខរាវិរុទ្ធខ្មែរ” លោកបណ្ឌិតសាស្ត្រាចារ្យ ច័ន្ទ សំណព្វ ឥតបានការពារ “ទំនាញសូរពិតប្រាកដ” ដែលជំនួសជាទូទៅព្យញ្ជនៈ“ណ”និង“ឡ”ដោយព្យញ្ជនៈ“ន”និង“ល”ទេ ដូច្នេះហើយ ខ្ញុំក៏បានធ្វើបុព្វកថាជូនគាត់ទៅ (បើគាត់ការពារ “ទំនាញសូរពិតប្រាកដ” ដែលខ្ញុំទើបបានបញ្ជាក់ខាងលើនេះ ខ្ញុំប្រាកដជាឥតព្រមធ្វើបុព្វកថាឱ្យគាត់ឡើយ)។

- maison បើគ្មានការសម្របសូរ គេត្រូវអាន [mɛsɔ̃] ប៉ុន្តែ ដោយមានការសម្របសូរ គេអានថា [mɛzɔ̃]។
- ពាក្យសម្គាល់មជ្ឈមណ្ឌលបច្ចេកវិទ្យារបស់ក្រសួងការពារជាតិនៃសហរដ្ឋអាម៉េរិក ហៅ NASA ត្រូវបានជនជាតិអាម៉េរិកាំង ( ទាំងអាម៉េរិកាំង ទាំងជនជាតិនៃប្រទេសឯទៀតដែលប្រើភាសាអង់គ្លេស) អានថា [næsə] ប៉ុន្តែ ជនជាតិបារាំងអានថា [naza][៨];

## III.២.២- **<u>ទំនាញសូរ</u>**

ប្រវត្តិសាស្ត្របានកន្លងទៅ ហើយ ពាក្យខ្លះក៏ត្រូវបានបង្កើតឡើងក្នុងបរិបទមួយ ដែលស៊ីចង្វាក់គ្នានឹងព្រឹត្តិការណ៍ គឺពាក្យ“ទំនាញសូរ” ដែលកើតឡើងរវាងឆ្នាំ១៩៧១ នៅពេលដែលគេបានសម្រេចជំនួសជាទូទៅព្យញ្ជនៈ“ណ”និង“ឡ”ដោយព្យញ្ជនៈ“ន”និង“ល”។ ចំពោះសាធារណជនភាគច្រើន “ទំនាញសូរ” គឺការជំនួសព្យញ្ជនៈ“ណ” និង“ឡ”ដោយព្យញ្ជនៈ“ន”និង“ល”នេះឯង ដែលបាននាំឱ្យមានកំណែអក្ខរាវិរុទ្ធនៃវចនានុក្រមសម្តេច **ជួន ណាត** អស់៣០៨ពាក្យ (១៩០ពាក្យពាក់ព័ន្ធនឹង“ន”ដែលជំនួស“ណ”និង១១៨ពាក្យពាក់ព័ន្ធនឹង“ល”ដែលជំនួស“ឡ”)។ ដើម្បីឱ្យសម្តីខ្ញុំមានភាពជាក់ស្តែង ខ្ញុំសូមជូនឧទាហរណ៍មួយចំនួន ដូចមានខាងក្រោម ៖

(១)- ឧទាហរណ៍ពាក់ព័ន្ធនឹង“ណ”ជំនួសដោយ“ន” ៖

(១.១)- កំណាត់ ជំនួសដោយ កំនត់

(១.២)- កំណាច ជំនួសដោយ កំនាច

(១.៣)- ចំណោះ ជំនួសដោយ ចំនេះ

(១.៤)- ចំណែក ជំនួសដោយ ចំនែក

(១.៥)- ដំណើរ ជំនួសដោយ ដំនើរ

(១.៦)- ដំណែង ជំនួសដោយ ដំនែង

(១.៧)- បំណាង ជំនួសដោយ បំនង

(១.៨)- បំណុល ជំនួសដោយ បំនុល

(១.៩)- សំណាប ជំនួសដោយ សំនាប

(១.១០)- សំណូក ជំនួសដោយ សំនូក

(២)- ឧទាហរណ៍ពាក់ព័ន្ធនឹង“ឡ”ជំនួសដោយ“ល” ៖

(១.១)- ក្រឡ ជំនួសដោយ ក្រល

(១.២)- ក្រឡុក ជំនួសដោយ ក្រលក

(១.៣)- ច្រឡឹង ជំនួសដោយ ច្រលឹង

(១.៤)- ច្រឡំ ជំនួសដោយ ច្រលំ

(១.៥)- ប្រឡាក់ ជំនួសដោយ ប្រលាក់

---

[៨] : ខ្ញុំមិនផ្តល់ឧទាហរណ៍ឱ្យបានច្រើននិងមិនពន្យល់ឱ្យបានសព្វគ្រប់ ពីព្រោះ តាមរយៈឧទាហរណ៍នេះ ខ្ញុំគ្រាន់តែចង់បង្ហាញថា ក្នុងចំណោមភាសារាប់ពាន់ គ្មានអ្នកប្រាជ្ញណាម្នាក់ឯងអាចចេះឬយល់ដល់ជម្រៅអំពីលក្ខណៈភាសាទាំងនោះអស់ទេ។

(១.៦)- ប្រឡាយ ជំនួសដោយ ប្រលាយ

(១.៧)- សំឡេង ជំនួសដោយ សំលេង

(១.៨)- សំឡេះ ជំនួសដោយ សំលេះ

(១.៩)- ស្រឡោច ជំនួសដោយ ស្រលោច

(១.១០)- ស្រឡៅ ជំនួសដោយ ស្រលៅ

ពាក្យទាំងប៉ុន្មានខាងលើនេះ និង ពាក្យចំនួន១៨៨ទៀត ដូចមានក្នុងបញ្ជីសរុប ត្រូវបានសរសេរខុសពីអក្ខរាវិរុទ្ធដែលមានក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** ហើយ ដែលគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) មុននឹងបានក្លាយទៅជាក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) បានអនុម័តឱ្យឈប់ប្រើហើយយកអក្ខរាវិរុទ្ធដើមវិញ។

## IV. **ទស្សនៈសម្តេច ជួន ណាត ទាក់ទងនឹងការខ្វះចន្លោះដែលអាចមានក្នុងវចនានុក្រមរបស់ព្រះអង្គ**[៩]

ត្រង់ប្រការនេះ ខ្ញុំសូមបញ្ជាក់ថា គប្បីកុំច្រឡំព្រះបន្ទូលរបស់ព្រះអង្គទាក់ទងនឹងការខ្វះចន្លោះ ដែលព្រះអង្គបានជ្រាបជាមុនថា វាមុខជានឹងមានក្នុងវចនានុក្រមរបស់ព្រះអង្គ និង ព្រះបន្ទូលទាក់ទងនឹងព្យាង្គតម្រួតនៃពាក្យកម្ចាយកើតចេញពីពាក្យដើមដែលសរសេរនឹងអក្សរតម្រួតឬផ្ញើជើង។

ចំពោះការខ្វះចន្លោះដែលព្រះអង្គបានជ្រាបជាមុនថា វាមុខជានឹងមានមិនខាននោះ ព្រះអង្គបានមានព្រះបន្ទូលដូចនេះ ៖ “(...)បើប្រៀបធៀបទៅនឹងផ្លូវ ក៏មានឋានៈត្រឹមតែប្រហែលនឹងថ្នល់លំដែលបានចាក់រាយក្រួសបាយក្រៀមស្តើងៗប៉ុណ្ណោះ ពុំទាន់មានឋានៈស្មើនឹងថ្នល់ដែលចាក់ជ័រយ៉ាងក្រាស់រលើបរលង់នៅឡើយទេ (...)” កុំទុកវចនានុក្រមនេះឲ្យនៅរសេមរសាមច្រើនពេក នាំឲ្យពិបាកប្រើ(...)[១០]។

ប៉ុន្តែ ដូចខ្ញុំបានបង្ហើបម្តងហើយនៅខាងដើម បញ្ហាដែលចោទគឺព្រំដែនរវាងការធ្វើ “ថ្នល់លំ” របស់សម្តេច **ជួន ណាត** ឱ្យក្លាយទៅជា “ថ្នល់ដែលចាក់ជ័រយ៉ាងក្រាស់រលើបរលង់” និង ការកែបំផ្លាញ “ថ្នល់លំ” នោះ។

បើខ្ញុំមានអំនួតចង់ឱ្យអ្នកខ្លះសរសើរខ្ញុំថាជាមនុស្សអស្ចារ្យ ចេះមើលឃើញអ្វីដែលអ្នកឯទៀតមើលមិនឃើញហើយ ឆ្លៀតលីលាយកសម្បត្តិកម្មរបស់ខ្ញុំទៅអនុវត្តនិងបោះពុម្ពផ្សាយយ៉ាងទូលំទូលាយនោះ ខ្ញុំប្រាកដជាបំផ្លាញអក្សរខ្មែរនិងអក្ខរាវិរុទ្ធនៃភាសាខ្មែរហើយ ទោះបីបើខ្ញុំគ្មានឱកាសបង្ខំគេឲ្យធ្វើតាមក៏ដោយ ពីព្រោះការរើរុះបែបនេះជា “របួសក្នុងសាច់” នៃអក្សរនិងអក្ខរាវិរុទ្ធនៃភាសាខ្មែរ ដក់ជាប់ក្នុងស្មារតីនៃអ្នាន(អ្នកអាន)។

ស្របទិសគ្នានេះ ការអនុវត្តណា ដែលចង់បំបាត់អក្សរខ្មែរមួយតួក្តី ពីរតួក្តី និង ដែលនាំឱ្យមានការប្រែប្រួលក្នុងអក្ខរាវិរុទ្ធនៃភាសាខ្មែរដែលមានស្រាប់ក្នុងវចនានុក្រម ក៏ជាការបំផ្លាញដែរ ដូចជា ការចង់បំបាត់អក្សរ“ណ”និង

---

[៩] : អ្នកដែលធ្លាប់ធ្វើសារណាឬនិក្ខេបបទ បានយល់ច្បាស់ហើយថា គេមិនដែលចាត់ទុករោងពុម្ព/គ្រឹះស្ថានទទួលបន្ទុកបោះពុម្ពផ្សាយថាជាម្ចាស់នៃស្នាដៃណាមួយទេ ៖ ម្ចាស់ស្នាដៃគឺអ្នកនិពន្ធដែលបានរៀបចំស្នាដៃនោះឡើង។ ចំពោះវចនានុក្រមខ្មែរ តាមភាពជាក់ស្តែង ដោយសារវចនានុក្រមនេះត្រូវបានធ្វើជាក្រុម គេត្រូវដាក់ថា “រៀបរៀងក្រោមការដឹកនាំរបស់សម្តេច **ជួន ណាត**” ប៉ុន្តែ ដោយនៅពេលចុងក្រោយ វចនានុក្រមត្រូវបានបញ្ចប់ដោយព្រះអង្គតែមួយអង្គឯង បើយើងថាជារបស់ព្រះអង្គក៏មិនខុសដែរ។

[១០] : ស្រង់ចេញពី “**និទាន**”ដ.ឯ.ម. ទំព័រ ង និង ច។

“ឡ”ជាដើម ដោយជំនួសជាទូទៅអក្សរ“ណ”និង“ឡ”ដោយអក្សរ“ន”និង“ល”ទោះក្នុងបំណងល្អយ៉ាងណាក៏ដោយ។ អ្នកដែលចង់កែអក្ខរាវិរុទ្ធសុទ្ធតែជាអ្នកស្រឡាញ់ភាសាជាតិ ប៉ុន្តែ មានតែការកែសម្រួល (មិនកែបំផ្លាញ) ក្នុងក្រប ខណ្ឌក្រុមប្រឹក្សាជាតិភាសាខ្មែរ (ថ្នាក់ជាតិ)ទេ ទើបការជ្រុលជ្រួសរបស់បុគ្គលណាម្នាក់អាចមានការទប់ទល់ពីសំណាក់សមាជិកឯទៀត។

ផ្ទុយពីប្រការខាងលើ សំណើធ្វើឡើងកាលពីថ្ងៃពុធ ទី១២ ខែតុលា ឆ្នាំ២០១១ ទាក់ទងនឹងការប្រើសំយោគសញ្ញា ដែលមិនទាន់មានក្បួនច្បាស់លាស់ ហើយ ដែលក.ជ.ភ.ខ.កំពុងរកឱកាសសុំការឯកភាពពីសម្តេចបណ្ឌិតសភាចារ្យតេជោប្រមុខរាជរដ្ឋាភិបាល តាមរយៈឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** អាចចាត់ទុកថាជាការកែសម្រួល“ផ្តល់លំ” ឱ្យទៅជា “ផ្តល់ដែលចាក់ជ័រយ៉ាងក្រាស់រលើបរលង់” តាមព្រះបន្ទូលរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ពីព្រោះវាទាក់ទងនឹងក្បួនដែលមិនទាន់ច្បាស់លាស់ផង, ដោយយើងបានពិនិត្យពិចារណាដោយប្រុងប្រយ័ត្នជាច្រើនលើកផង និង ដោយយើងមិនហ៊ានយកជាបានការមុនមានការឯកភាពពីរាជរដ្ឋាភិបាលផង។

## V. <u>ទស្សនៈរបស់សម្តេច ជួន ណាត ទាក់ទងនឹងព្យញ្ជនៈតម្រួតនៃពាក្យកម្លាយកើតចេញពីពាក្យដើមដែលសរសេរជាអក្សរតម្រួតឬផ្ញើជើង</u>[១១]

ព្យញ្ជនៈរាយនិងព្យញ្ជនៈតម្រួតបានចោទនិងកំពុងចោទជាបញ្ហាចម្រូងចម្រាសក្នុងចំណោមអ្នកប្រើប្រាស់អក្ខរាវិរុទ្ធភាសាខ្មែរ។ ខ្ញុំសូមរួមចំណែកក្នុងការពិចារណាលើបញ្ហានេះ ដើម្បីបានជាទុនសម្រាប់ពិគ្រោះយោបល់គ្នាជាមួយសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.) ប៉ុន្តែ ដោយបញ្ហានេះត្រូវបានផ្សព្វផ្សាយជាសាធារណៈយ៉ាងទូលំទូលាយរួចមកហើយ តាមរយៈសៀវភៅផង និង តាមវិទ្យុផង ខ្ញុំត្រូវឆ្លើយតាមមធ្យោបាយដូចគ្នាសិន មុននឹងដាក់ឱ្យក.ជ.ភ.ខ.អនុម័ត។

ចំពោះព្យញ្ជនៈតម្រួតដូចមានចែងក្នុងចំណងជើងខាងលើ សម្តេច **ជួន ណាត** បានមានព្រះបន្ទូល ដូចតទៅ “ខ១២-កិរិយាសព្ទឬគុណសព្ទដែលមាន<u>អក្សរ</u>តម្រួតឬ<u>ផ្ញើជើងគួរវាត់</u>[១២] ដល់ចេញមកជានាមសព្ទ ត្រូវតម្រួត[១៣] ដូចជា ក្រង កិ.> កម្រង ន. ; ក្រាស់ គុ. > កម្រាស់ ន. ; ស្ដី កិ. > សម្ដី ន.។ ល។ កិរិយាសព្ទជាកត្តុវាចក (សម្រេចអំពើខ្លួនឯង)ចេញទៅជាកិរិយាសព្ទជាហេតុកត្តុវាចក (ញ៉ាំងអ្នកដទៃឱ្យសម្រេចអំពើ) ក៏មានដូចជា ខ្ចាត់ កិ.(កត្តុ.) > កម្ចាត់ កិ.(ហេតុ.) ; ខ្ចាយ កិ.(កត្តុ.) > កម្ចាយ កិ. (ហេតុ.)។ ល។ <u>ប៉ុន្តែ សព្ទខ្លះដែល</u>

---

[១១] : សម្តេច **ជួន ណាត** មិនច្រឡំ “អក្សរតម្រួតឬផ្ញើជើង” និង “ព្យញ្ជនៈតម្រួត”ទេ, ឧ. “ស្ដី”ជាពាក្យសរសេរដោយអក្សរតម្រួតឬផ្ញើជើង មិនមែនជាព្យញ្ជនៈតម្រួតទេ។ ដើម្បីតម្រួតព្យញ្ជនៈបានលុះណាមានព្យញ្ជនៈពីរទើបគេអាចដាក់ព្យញ្ជនៈមួយលើព្យញ្ជនៈមួយទៀតបាន, ឧ. ពាក្យ “សម្ដី”។ ដោយមានការភ្លាំងភ្លាត់ ខ្ញុំបានច្រឡំប្រើពាក្យ “ព្យញ្ជនៈតម្រួត” ជំនួសពាក្យ “អក្សរតម្រួត” (សូមសាធារណជនមេត្តាអភ័យទោស និង សូមអានទំព័រ៤ ខ្ទង់ទី៣ នៃព្រឹត្តិបត្រលេខ២របស់ ក.ជ.ភ.ខ)។

[១២] : គំនូសពីក្រោមត្រូវបានគូសដោយអ្នកនិពន្ធនៃសិក្ខាកថា។

[១៣] : តាមបរិបទ យើងអាចសន្និដ្ឋានបានថា “ត្រូវតម្រួត” មានន័យថា “ត្រូវប្រើព្យញ្ជនៈតម្រួត” (ខុសពីអក្សរតម្រួត)។

<u>តម្រូតពុំកើតក៏មាន</u> ដូចជា ភ្លឺ កិ.(កត្តុ.) >បំភ្លឺ កិ.(ហេតុ. ) ; ផ្អើស កិ.(កត្តុ.) > បំផ្អើស កិ.(ហេតុ.); ឃ្លាត កិ.(កត្តុ.) > បង់ឃ្លាត កិ. (ហេតុ. )[១៤]។ល។

"ត្រង់ ខ ១២- ដែលបានពោលហើយដែរ យើងសម្រេចថា ក្រាល កិ. > កម្រាល ន. ; ក្រាស់ គុ. > កម្រាស់ ន. ; ខ្ចាត់ កិ. (កត្តុវាចក គឺខ្ចាត់ឯង ) > កម្ចាត់ កិ. (ហេតុកត្តុវាចក គឺញុំាងអ្វីៗឱ្យខ្ចាត់) ; ខ្ចាយ កិ. (កត្តុ.) > កម្ចាយ កិ. (ហេតុ.) ; ខ្ពិល គុ. > កម្ពិល ន. ; គ្រប កិ. > គម្រប ន. ; ឃ្លាន កិ. > គម្លាន ន. ; ច្រូត កិ. > ចម្រូត ន. ; ជ្រក កិ. > ជម្រក ន. (...) <u>ប៉ុន្តែមេពាក្យទាំងអស់នេះជាដើម ដែលធ្លាប់តែសរសេរវាយតួថ្មីកដែមកយូរហើយ យើងក៏ពុំទាន់ប៉ានសម្រេចតាមយោបល់នោះដោយដាច់ខាតដែរទេ, បើត្រូវការសរសេរវាយតួជា កំរាល, កំរាស់។ល។ តាមទម្លាប់នោះសិន</u>[១៥]<u>ទៅក៏បាន ទោះបីក្នុងវចនានុក្រមនេះ យើងបានសម្រេចជាមេពាក្យតម្រូតហើយក៏ដោយ</u>[១៦]។ល។[១៧]"។

<u>កំណត់សម្គាល់</u> ៖ សម្ដេច **ជួន ណាត** បានទុកពេលឱ្យគេសរសេរជាព្យាង្គវាយតាមទម្លាប់ "<u>សិនចុះ</u>" ចំពោះពាក្យណាដែលព្រះអង្គបានយល់ថាគួរសរសេរជាព្យាង្គតម្រូត។ ប៉ុន្តែ "ការសរសេរជាព្យាង្គវាយតាមទម្លាប់<u>សិនចុះ</u>" បានកន្លងមកអស់រយៈពេល៤៥ឆ្នាំហើយ ហើយ អាចបន្តទៅទៀត[១៨]។

## VI. <u>អំពីព្យាង្គ</u>

តាមលោកសូសៀរ (Saussure) "ព្យាង្គជាសម្ព័ន្ធគ្រឹះដែលជាមូលដ្ឋានក្នុងការផ្គុំសទ្ទតាឱ្យកើតជាពាក្យសម្ដីឡើង។ សម្ព័ន្ធគ្រឹះនេះឋិតនៅលើភាពខុសគ្នារវាងសទ្ទតា ដែលគេហៅថា ព្យញ្ជនៈនិងស្រៈ"។ និយមន័យនៃព្យាង្គតាម ភាសាវិទ្យាឱ្យគ្រប់ដណ្ដប់គ្រប់ភាសាក្នុងលោកជាការពិបាក ហើយ ត្រូវការការពន្យល់ជាច្រើនទំព័រ។ ប៉ុន្តែនិយមន័យសម្រាប់ភាសាណាមួយមិនពិបាកពេកទេ។ អ្នកសិក្សាអំពីភាសាខ្មែរសុទ្ធតែព្រមទទួលស្គាល់ថា ព្យាង្គនៃពាក្យខ្មែរត្រូវ មានស្រៈជាស្នូល។

អក្សរកាត់ ៖ ស = ស្រៈ
ព = ព្យញ្ជនៈ។

ព្យាង្គខ្មែរមាន ៖

(១)- ស (ដូចពាក្យឯកព្យាង្គ"អ៊ី"ដែលយើងនិយមហៅតាមចិន ឬ ព្យាង្គ"អា-" ក្នុងពាក្យ"អាណិត"...);

(២)- ពស (ដូចពាក្យឯកព្យាង្គ"តា" ឬ ព្យាង្គ "បា-" ក្នុងពាក្យ"បារម្ភ"...);

---

[១៤] : ស្រង់ចេញពី "**និទាន**" ជ.ឯ.ម., ទំព័រ គ។

[១៥] : គំនូសពីក្រោមត្រូវបានគូសដោយអ្នកនិពន្ធនៃសិក្សាកថា។

[១៦] : គំនូសពីក្រោមត្រូវបានគូសដោយអ្នកនិពន្ធនៃសិក្សាកថា។

[១៧] : ស្រង់ចេញពី "**និទាន**" ជ.ឯ.ម., ទំព័រ ឆ។

[១៨] : គំនូសពីក្រោមត្រូវបានគូសដោយអ្នកនិពន្ធនៃសិក្សាកថា។

(៣)- ពពស (ដូចពាក្យឯកព្យាង្គ"ត្រា" ឬ ព្យាង្គ "ស្វា-"ក្នុងពាក្យ"ស្វាហាប់"...) ;

(៤)- សព (ដូចពាក្យឯកព្យាង្គ"ឥត" ឬ ព្យាង្គ"អាក់-" ក្នុងពាក្យ"អាក់ខាន"...);

(៥)- ពសព (ដូចពាក្យឯកព្យាង្គ"ចាន" ឬ ព្យាង្គ"បន-" ក្នុងពាក្យ"បនល្បែង"...);

(៦)- ពពសព (ដូចពាក្យឯកព្យាង្គ"ស្វាយ" ឬ ព្យាង្គ "គ្រាន់-" ក្នុងពាក្យ"គ្រាន់បើ"...)។

ភាសាជាសូរ ដូច្នេះ ពាក្យនិងព្យាង្គរបស់វាក៏ជាសូរដែរ។ អក្សរគ្រាន់តែជាឧបករណ៍សម្រាប់កត់សូរទាំងនោះប៉ុណ្ណោះ។ ការកត់សូរព្យាង្គមានច្រើនបែប ដែលអ្នកស្រាវជ្រាវខ្លះបានខំស្វែងរកក្បួនដើម្បីឱ្យអ្នកប្រើអក្ខរាវិរុទ្ធងាយចាំក្នុងការសរសេរ ប៉ុន្តែ ក្បួនខ្លះមានលក្ខណៈអត្តវិស័យខ្លាំងពេក មិនអាចមានប្រយោជន៍ដល់អ្នកប្រើអក្ខរាវិរុទ្ធទេ ជាពិសេស បើគេមិនញែកឱ្យច្បាស់រវាងសូរនិងសញ្ញាដែលកត់ត្រាសូរ កាលណាការកត់ត្រានោះល្អៀងឆ្ងាយពីសូរ ឬ ឥតមានការកត់ត្រា (ក្នុងករណីស្រៈកប់)។ ផ្អែកលើសូរសុទ្ធសាធ ព្យាង្គមានតែទម្រង់ដូចដែលខ្ញុំទើបបានបង្ហាញខាងលើ ហើយ សូរវិទូចាប់អារម្មណ៍ខ្លាំងទៅលើព្យាង្គពីរប្រភេទ គឺព្យាង្គដែលមានស្រៈនៅចំហខាងចុង ហៅថា "ព្យាង្គបើក" ដូច "តា", ក្រមា,... និង ព្យាង្គដែលមានព្យញ្ជនៈប្រកបនៅខាងចុង ហៅថា "ព្យាង្គបិទ" (បិទដោយព្យញ្ជនៈ) ដូចពាក្យ "ចាន", រីករាយ,...។

ដោយសូរនេះត្រូវបានគេកត់ត្រាដោយសញ្ញា (អក្សរ) ដែលអាចមិនសូវចំនឹងសូរ នៅពេលខ្លះ គេត្រូវបញ្ជាក់ថា ជា"សញ្ញាព្យញ្ជនៈ/សញ្ញាស្រៈ" ឬ ជា "សូរព្យញ្ជនៈ/សូរស្រៈ" ដើម្បីកុំឱ្យមានការភាន់ច្រឡំ (ឧ. ក្នុងពាក្យ "កង"ដោយសារមានស្រៈ "អ" កប់ក្នុងព្យញ្ជនៈ "ក" គេមិនឃើញមានសញ្ញាស្រៈ "អ" ទេ)។

ក្នុងភាសាបារាំងមានព្យាង្គ"ពពពសព" ផងទៀត ដូចក្នុងពាក្យ Strophe [strof] រីឯពាក្យសំស្ក្រឹតសុទ្ធសាធ "ស្ត្រី" ដែលខ្មែរនិយមប្រើដោយគោរពជំនួសពាក្យ "ស្រី" (សំស្ក្រឹតក្លាយ) ក៏អាចចាត់ទុកថា ជាព្យាង្គដែលមានទម្រង់ "ពពពសព" ផងដែរ គឺ [strej]។

ពិតមែនហើយ ព្យាង្គតម្រួតឥតមានទំនាក់ទំនងអ្វីនឹងអក្ខរាវិរុទ្ធ បារាំង អង់គ្លេស ឬ ថៃទេ (ពីព្រោះគេគ្មានជើងអក្សរសម្រាប់ដាក់នៅក្រោមតួអក្សរ) ប៉ុន្តែ សូរវិទូក៏មានភារកិច្ចពិនិត្យឱ្យដឹងថាពាក្យណាមានមួយព្យាង្គ ពាក្យណាមានពីរព្យាង្គ ឬ លើសពីនេះ។ល។ សូរវិទូក្នុងលោកយល់ស្របគ្នាថា ពាក្យបារាំង ដូចជា trop [tro], stade [stad],... ពាក្យ អង់គ្លេស ដូចជា strip [strip], bring [briŋ],... ជាពាក្យឯកព្យាង្គ ដូច្នេះ ពាក្យខ្មែរ ដូចជា "ជ្រាប", ក្លាន,... ក៏ជាពាក្យឯកព្យាង្គដែរ ហើយ ក្នុងករណីដែលមានព្យាង្គតែមួយបែបនេះ គេមិនអាចថាជាព្យាង្គតម្រួតបានទេ ពីព្រោះគេអាចតម្រួតព្យាង្គបានលុះណាមានព្យាង្គពីរយ៉ាងតិច។ ចំពោះពាក្យដូច "ជ្រាប", ក្លាន,... សម្ដេច **ជួន ណាត** ព្រះអង្គហៅថា ជាពាក្យសរសេរជាមួយ "អក្សរតម្រួតឬផ្ញើជើង"[១៩]។

---

[១៩] : គំនូសពីក្រោមត្រូវបានគូសដោយអ្នកនិពន្ធសិក្សាកថា។

## VII. សម្រង់កំហុសចុះការភ្លាំងភ្លាត់ដែលមានក្នុងវចនានុក្រម សម្ដេច ជួន ណាត

ក្រោយពីបានអានចំណុច IV នៃសិក្សាកថាខ្ញុំនេះហើយ សាធារណជនខ្មែរណាក៏អាចយល់ពីព្រះទ័យមិនចង្អៀត ចង្អល់និងទន់ភ្លន់របស់សម្ដេច **ជួន ណាត** ដែរ ប៉ុន្តែ យើងក៏គប្បីយល់ដែរថា ព្រះអង្គបានរៀបចំវចនានុក្រមនេះឡើងជាមួយក្រុមរបស់ព្រះអង្គ ដោយផ្អែកលើកគោលការណ៍មួយចំនួន ទោះបីគោលការណ៍ខ្លះមានការខ្វះចន្លោះក៏ដោយ[២០]។

ដោយសម្ដេច **ជួន ណាត** បានសុំឱ្យខ្មែរជំនាន់ក្រោយជួយកែសម្រួលវចនានុក្រមរបស់ព្រះអង្គ សមាជិកនៃ ក.ជ.ភ.ខ. អាចស្នើគំនិតរបស់ខ្លួនមកស្ថាប័ននេះ ដើម្បីសម្រេចជាមួយគ្នា យកគោលជំហររួម មិនត្រូវសាបព្រោះគំនិតផ្ទាល់ខ្លួនផ្សេងៗគ្នាតាមសំណេរឬតាមសម្ភាសន៍ក្នុងទូរទស្សន៍ឬក្នុងវិទ្យុឡើយ ពីព្រោះការធ្វើបែបនេះនាំឱ្យសាធារណជនខ្មែរវិលវល់។ លទ្ធផលស្រាវជ្រាវគប្បីផ្សាយក្នុងមជ្ឈដ្ឋានអ្នកស្រាវជ្រាវសិន។ ការស្នើអំពីការប្រើសំយោគសញ្ញាជាឧទាហរណ៍មួយដ៏ប្រសើរ ដែលសមាជិកក.ជ.ភ.ខ.គួរធ្វើតទៅទៀត។

សម្ដេច **ជួន ណាត** និងក្រុមព្រះអង្គ បានធ្វើវចនានុក្រមខ្មែរជាលើកដំបូង ចាប់ពីបាតព្រះហស្ដទទេ។ សព្វថ្ងៃ យើងមានបង្អែកតាមរយៈវចនានុក្រមនេះផង និង តាមរយៈវចនានុក្រមឯទៀតៗផង។ យើងមានការងាយស្រួលច្រើនណាស់ក្នុងការធ្វើវចនានុក្រមថ្មីមួយឱ្យមានពាក្យច្រើនទាន់បច្ចុប្បន្នភាពផង និង ចៀសការភ្លាំងភ្លាត់របស់វចនានុក្រមមុនៗផង ប៉ុន្តែ សូមចាំកុំភ្លេចថា ការកែសម្រួលឱ្យរីកចម្រើនមិនមែនជាការកែបំផ្លាញនោះឡើយ។

### VII.១- សម្រង់ការភ្លាំងភ្លាត់មួយគ្រាន់តែជាឧទាហរណ៍ដែលបង្ហាញថា សម្ដេច ជួន ណាត បានជ្រាបច្បាស់ណាស់ថា វចនានុក្រម១.៨៥៨ទំព័រមិនអាចចៀសការភ្លាំងភ្លាត់ខ្លះៗបានទេ

ខ្ញុំសុំលើកតែការភ្លាំងភ្លាត់មួយក្នុងវចនានុក្រមរបស់សម្ដេច **ជួន ណាត** មកនិយាយ។ ព្រះអង្គបានសរសេរពីរយ៉ាងនូវពាក្យ "សព្ទ"/"ស័ព្ទ"។ តាមតក្កភាព ពាក្យផ្សំជាមួយនឹងពាក្យ"សព្ទ/ស័ព្ទ"នេះ ក៏ត្រូវសរសេរបានពីរយ៉ាងដែរ, ប៉ុន្តែ ព្រះអង្គបានដាក់តែពាក្យ"**ទូរស័ព្ទ**" ជា**មេពាក្យ** ហើយ យើងត្រូវរង់ចាំមើលបន្ទាត់១៥និង១៦នៃទំព័រ ១.១៨៦ ទើបឃើញពាក្យ"**ទូរសព្ទ**"(សរសេរឥតមានសំយោគសញ្ញា) គឺ " **វិទ្យុទូរសព្ទ, ទូរសព្ទតាមវិទ្យុ, ទូរសព្ទឥតខ្សែ**"។ បើគ្មានការភ្លាំងភ្លាត់ទេ ព្រះអង្គប្រាកដជាចុះមេពាក្យថា "ទូរសព្ទ" ឬ "ទូរស័ព្ទ" រួចទៅហើយ។ ប៉ុន្តែ ការភ្លាំងភ្លាត់ខ្លះៗក្នុងវចនានុក្រមដែលមាន១.៨៥៨ទំព័រ រៀបចំឡើងដំបូងគេ ដោយពុំមានវចនានុក្រមណាជាបង្អែកផងនោះ ត្រូវចាត់ទុកជាស្នាដៃដ៏មហាស្ចារ្យមួយ (សិក្សាកថារបស់ខ្ញុំដែលមានប្រហែលជា២០ទំព័រ ប្រាកដជាមានការភ្លាំងភ្លាត់មួយចំនួនមិនខាន)។

---

[២០] : ដោយព្រះអង្គមានគោលការណ៍បានជាគោលការណ៍នេះបានប៉ះនឹងគោលការណ៍របស់លោក កេង វ៉ាន់សាក់។

## VII.២- <u>ការទ្លាំងទ្លាត់ឬកំហុសស្រង់ដោយអ្នកនិពន្ធ“សំណោរនិងអក្ខរាវិរុទ្ធខ្មែរ”</u>

### VII.២.១- <u>ការទិតៀនដោយឆាន់ច្រឡំឬដោយយកការទ្លាំងទ្លាត់របស់សម្តេច ជួន ណាត ជាកំហុសដ៏ធ្ងន់ធ្ងរ</u>

ចំពោះពាក្យកម្លាយកើតចេញពីពាក្យដើមសរសេរជាមួយ<u>អក្សរ</u>តម្រួតឬ<u>ផ្ញើជើង</u> តាមរយៈផ្នត់ដែក /-អ៉ម-/ ឬ /-អ៊ំម-/ លោកបណ្ឌិតសាស្ត្រាចារ្យ ច័ន្ទ សំណព្វ អ្នកនិពន្ធ “សំណោរនិងអក្ខរាវិរុទ្ធខ្មែរ[២១]” បានសង្កេតថា ព្រះអង្គមិនទាំងបានអនុវត្តក្បួនរបស់ព្រះអង្គជាទូទៅផង ដោយសរសេរជាព្យាង្គរាយ នូវពាក្យខាងក្រោម ៖

- សំណាក់,
- សំណើ,
- ចំពោះ។

តាមពិត ពាក្យ“សម្នាក់” មានក្នុងវចនានុក្រម ហើយ ពាក្យ“សំណើ” ក្នុងវចនានុក្រម មិនមែនចេញពីពាក្យ “ស្នើ”ទេ។ ព្រះអង្គបានពន្យល់ពាក្យ“សំណើ” ដូចនេះ “សំណើ *ន.* ពេល, វេលាដ៏ខ្លី មានរយៈប្រហែលដូចគេសើឱ្យឃើញស្មើឃើញស្រទាប់ : *ត្រូវប្រើរបស់ហ្នឹងមួយសំណើទៅសិន ទម្រាំបានរបស់ថ្មីមកទៀត*”[២២]។ រីឯពាក្យ “ចម្ពោះ” វិញ គឺជាការភ្លាំងភ្លាត់ដែលនាំឱ្យយើងរង់ចាំមើលបន្ទាត់ទី១៧នៃទំព័រ១.២៩១ ទើបឃើញពាក្យនេះ ដូចតទៅ ៖ “សម្បសាទ (សម-ប៉ះសាត) *ន.* (បា.; សំ. *សំប្រសាទ* ឬ *សម្ប្រ–*) សេចក្តីជ្រះថ្លាខ្លាំង ; សេចក្តីជឿទុកចិត្តឥតរង្កៀស ៖ *ឱ្យទានដោយសម្បសាទ; មានសម្បសាទ**ចម្ពោះ**មិត្រសម្លាញ់* (ប្រើជា *សម្បសាទន៍* ក៏បាន)”។ បើគ្មានការភ្លាំងភ្លាត់ទេ ប្រហែលជាព្រះអង្គបានដាក់ជាមេពាក្យ “ចំពោះ” ឬ “ចម្ពោះ” រួចទៅហើយ ដូចពាក្យឯទៀតមួយចំនួនដែលព្រះអង្គអនុញ្ញាតឱ្យសរសេរបានពីរយ៉ាងនោះដែរ។

អ្នកនិពន្ធ “សំណោរនិងអក្ខរាវិរុទ្ធខ្មែរ” បានបន្តទៀតថា ៖ “គោលការណ៍ដែលតម្រូវឱ្យសរសេរពាក្យកម្លាយដោយផ្អែកលើសំណោរនៃពាក្យឫសនេះមានអតក្កភាព ហើយ ពុំអាចចាត់ទុកជាគោលការណ៍សកលបានឡើយ ដោយហេតុថា វាមានភាពខុសឆ្គងជាច្រើន”[២៣]។

អ្នកនិពន្ធចង់ធ្វើឱភាសកម្ម ប៉ុន្តែ សម្តេច **ជួន ណាត** ឥតមានបំណងធ្វើឱភាសកម្មទេ ព្រះអង្គចង់បានតែព្យាង្គតម្រួតនៃពាក្យកម្លាយណាដែលកើតចេញពីពាក្យដើមដែលសរសេរជាមួយ<u>អក្សរ</u>តម្រួតឬ<u>ផ្ញើជើង</u>តាមរយៈ

---

[២១] : ច័ន្ទ សំណព្វ, សំណោរនិងអក្ខរាវិរុទ្ធខ្មែរ, រោងពុម្ព ហ្គូណាន ឆ្នាំ២០០៨ ទំព័រ ៧៧។

[២២] : គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ហៅកាត់ថា (គ.ប.ស.) បានសរសេរ “សម្នើ” កាលពីថ្ងៃប្រជុំមួយដែលខ្ញុំភ្លេចទៅ។

[២៣] : ច័ន្ទ សំណព្វ, សំណោរនិងអក្ខរាវិរុទ្ធខ្មែរ, រោងពុម្ពហ្គូណាន ឆ្នាំ២០០៨, ទំព័រ៧៩។

រូបតាដែលជាផ្នត់ដែក /-អ´ម-/ ឬ /-អ៊ិ´ម-/[២៨] ដែលមានកាឡារូប ដូចខាងក្រោម ៖

- [-អ´ង-]/[-អ៊ិ´ង-], ឧ. ខ្វល់ + [-អ´ង-] > កង្វល់;
- [-អ´ញ- ]/ [-អ៊ិ´ញ-], ឧ. ខ្ជប់ + [-អ´ញ- ] > កញ្ជប់;
- [-អ´ណ-]/ [-អ៊ិ´ណ-], ឧ. ប្ដឹង + [-អ´ណ-] > បណ្ដឹង;
- [-អ´ន-]/[-អ៊ិ´ន-], ឧ. ភ្លឹក + [-អ៊ិ´ន-] > ពន្លឹក;
- [-អ´ម-]/[-អ៊ិ´ម-], ឧ. គ្រប + [-អ៊ិ´ម-] > គម្រប, ខ្ចាត់ + [-អ´ម-] > កម្ចាត់។

ចំពោះកិរិយាហេតុ ដូច ភ្លឺ > បំភ្លឺ, ផ្លើស > បំផ្លើស,... ដែលគោលការណ៍អាស្រ័យឫសទាល់ច្រក ហើយបែរមករកព្យាង្គរាយនោះ វាជាករណីលើកលែងបែបវេយ្យាករណ៍ប្រពៃណី ជាពិសេស វេយ្យាករណ៍បារាំងដែលសម្បូណ៍ហូរហៀរដោយករណីលើកលែងនេះ។ **ប៉ុន្តែ បញ្ហាចម្បងនៅត្រង់ថា តើគោលការណ៍អាស្រ័យផ្នត់របស់អ្នកនិពន្ធ "សំណេរនិងអក្ខរាវិរុទ្ធខ្មែរ"អាចចៀសផុតពីករណីលើកលែងបានឬទេ។**

## VII.២.២- <u>ការធ្វើឱ្យនាសកម្មដោយផ្អែកលើការកែឡែន័យនៃពាក្យ"ព្យាង្គតម្រួត"ឱ្យមានន័យខុសពីន័យធម្មតា</u>

ដើម្បីឱ្យគោលការណ៍អាស្រ័យផ្នត់របស់គាត់មាន "លក្ខណៈសកល" អ្នកនិពន្ធ "សំណេរនិងអក្ខរាវិរុទ្ធខ្មែរ" បានកែប្រែលំហៅដែលខ្មែរទូទាំងប្រទេសធ្លាប់ស្គាល់។ ពាក្យឯកព្យាង្គ ដូចជា ក្រាប, ច្បូត, ឆ្កួត, ត្បារ,... ដែលសម្ដេច **ជួន ណាត** ហៅថា ពាក្យ "ដែលសរសេរជាមួយនឹង<u>អក្សរ</u>តម្រួតឬ<u>ផ្ញើជើង</u>" ត្រូវបានអ្នកនិពន្ធ "សំណេរនិងអក្ខរាវិរុទ្ធខ្មែរ" ហៅថាជា "ព្យាង្គតម្រួត"។ ចំពោះខ្មែរទូទៅក៏ដូចសម្ដេច **ជួន ណាត** ដែរ គេអាចហៅថា ព្យាង្គតម្រួតបាន លុះណាមានព្យាង្គពីរ (ដើម្បីឱ្យមានលទ្ធភាពដាក់ព្យាង្គមួយលើព្យាង្គមួយទៀត), ឧ. សម្ដី, កណ្ដាល, ជម្រាប, បញ្ចូល, សម្គម,...។

អ្នកនិពន្ធ"សំណេរនិងអក្ខរាវិរុទ្ធខ្មែរ"បានសរសេរ ដូចនេះ ៖

«**៣.២.១.១.១. ផ្នត់ដើមទម្រង់** [ព-]

ជាទូទៅ ផ្នត់ដើមទម្រង់ [ព-] នេះប្រើផ្សំនឹងឫសដែលសុទ្ធសឹងតែជាពាក្យសរសេរជាព្យាង្គរាយ ហើយវាតម្រូវឱ្យសរសេរពាក្យកម្លាយជាព្យាង្គតំរួតទាំងអស់។ (...)។ ឧទាហរណ៍ :

(១) [ក-] + បាំង > ក្បាំង

(...)

---

[២៨] : កាលណារូបតា (mophème) ណាមួយមានការប្ដូររូបបន្តិចបន្តួចទៅតាមបរិបទ ដោយរក្សាគ្រឹះដើម (ដូចក្នុងឧទាហរណ៍ខាងលើ ៖ [-អ´...-] ឬ [-អ៊ិ´...-]) ការផ្លាស់ប្ដូរនេះត្រូវគេហៅថា "កាឡារូប" (allomorphes) ហើយ គួរបញ្ជាក់ថា មានកាឡារូបក្នុងករណីជាច្រើនទៀត។ ក្នុងភាសាវិទ្យា បើមានកាឡារូបណាមានចំនួនច្រើនជាងគេ គេយកកាឡារូបនោះសម្រាប់តំណាងរូបតា ហើយ គេដាក់វាអមដោយបន្ទាត់ទ្រេត (ដូចខាងលើ)។ កាឡារូបទាំងប៉ុន្មានដែលចេញក្នុងពាក្យជាក់ស្ដែង គេដាក់វាក្នុងឃ្នាប (ដូចខាងលើ)។ គួរបញ្ជាក់ផងដែរថា រូបតាដែលចេញក្នុងពាក្យជាក់ស្ដែងណាមួយ ក៏ត្រូវចាត់ទុកជាកាឡារូបដែរ (ដូចខាងលើ)។

(២) [ច-] + បូត > ច្បូត

(...)

(៣) [ត-] + បារ > ត្បារ

(...)

(៤) [ប-] + ដាច់ > ផ្ដាច់

(...)

(៥) [ម-] + ដុំ > ម្ដុំ

(...)

(៦) [ស-] + កាត់ > ស្កាត់

### ៣.២.១.១.២. ផ្នត់ដើមទម្រង់ [ពសព-]

ផ្នត់ដើមទម្រង់ [ពសព-] ទាំងអស់សុទ្ធតែកម្លាយពាក្យឫសឱ្យបានទៅជាពាក្យដែលសរសេរជាតំរួតព្យាង្គទាំងអស់ ទោះបីពាក្យឫសនោះជាព្យាង្គរាយឬជាព្យាង្គតំរួតក៏ដោយ។ ចំពោះពាក្យកម្លាយតាមរយៈផ្នត់ដែលមានស្នូរ|អ់ម| ដូចជា |ក់ម| |ដ់ម|។ល។ គឺត្រូវសរសេរជារាយព្យាង្គ ប្រសិនបើគេកត់ត្រាស្នូរ |អ់ម| នោះដោយសញ្ញាដំណើ[២៥]។

(...)

(៧) [ច់ង-] + គ្រោង > ចង្គ្រោង

(៧ក) [ច់ង-] + អូរ > ចង្អូរ

(...)

(៨ក) [ដ់ង-] + ហក់ > ដង្ហក់

(៨ខ) [ដ់ង-] + ហែ > ដង្ហែ

(...)

(៩) [ប់ង-] + ក > បង្ក

(៩ក) [ប់ង-] + កើត > បង្កើត

(...)

(១០) [ព់ង-] + រត់ > ពង្រត់

[២៥] : បើគេប្រើសញ្ញា"ដំណើ"គេមិនអាចសរសេរជាព្យាង្គតម្រួតបានទេ ប៉ុន្តែ បញ្ហានៅត្រង់ថា តើយើងអាចសរសេរជាព្យាង្គរាយ ឬជាព្យាង្គតម្រួតតាមតែចំណង់របស់យើងឬយ៉ាងណា។

(១០ក) [ព´ង-] + រាយ > ពង្រាយ

(...)

(១១) [ស´ង-] + កាត់ > សង្កាត់

(...)

(១១ខ) [ស´ង-] + កត់ > សង្កត់

(...)

(១២គ) [វ´ង-] + វង់ > វង្វង់

(១២ឃ) [វ´ង-] + វាស់ > វង្វាស់

(...)

(១៣គ) [អ´ង-] + រុត > អង្រុត

(១៣ឃ) [អ´ង-] + រួស > អង្រួស

(...)

(១៤) [ក´ញ-] + ចាស់ > កញ្ចាស់

(...)

(១៤ខ) [ក´ញ-] + ឆែប > កញ្ឆែប

(...)

(១៥) [ប´ញ-] + ចប់ > បញ្ចប់

(...)

(១៥គ) [ប´ញ-] + ចុះ > បញ្ចុះ

(...)

(១៦) [ជ´ញ-] + ជក់ > ជញ្ជក់

(១៦ក) [ជ´ញ-] + ជូន > ជញ្ជូន

(...)

(១៧គ) [ក´ន-] + តុញ > កន្តុញ

(១៧ឃ) [ក´ណ-] + ដឹង > កណ្ដឹង

(១៧ង) [ក´ន-] + ត្រង > កន្ត្រង

(១៧ច) [ក់ន-][២៦] + តឿ > កន្តឿ

(...)

(១៨) [ប់ណ-] + ដើរ > បណ្ដើរ

(...)

(១៨ខ) [ប់ន-] + ត > បន្ត

(...)

(១៩ក) [ព់ន-] + យារ > ពន្យារ

(...)

(១៩ឃ) [ព់ន-] + លឿន > ពន្លឿន

(...)

(២០ក) [ស់ន-] + ឡប់ > សន្លប់

(២០ខ) [ស់ន-] + សើម > សន្សើម

(...)

(២១) [អ់ន-] + ទាក់ > អន្ទាក់

(...)

(២១គ) [អ់ន-] + លង់ > អន្លង់

(...)

**៣.២.១.១.៣. ផ្នត់ដែកទម្រង់ [-ន-]**

ផ្នត់ដែកទម្រង់ [-ព-] ទាំងអស់កម្លាយពាក្យឫសដែលជាព្យាង្គរាយឱ្យបានទៅជាពាក្យថ្មីដែលសុទ្ធតែសរ សេរជាព្យាង្គតំរួតទាំងអស់។ (...)

(២៣) [-ន-] + កើត > ខ្នើត

(...)

(២៣ខ) [-ន-] + គាប > ឃ្នាប

[២៦] : ផ្នត់ដើម[ក់ណ-]/[ក់ន-] ជាសទិសសូរ"វេយ្យាករណ៍វិស័យ"(homonymie grammaticale) ដូចបច្ឆិមបទបារាំង "eur"ដែរ ដែលជាបច្ឆិមបទពីរផ្សេងគ្នា (ក្នុង"blancheur" បច្ឆិមបទ "eur" សម្គាល់គុណភាព ប៉ុន្តែ ក្នុងពាក្យ "planteur" វាជាបច្ឆិមបទមួយទៀតសម្គាល់ភ្នាក់ងារ។ ចំពោះសទិសសូរ "វេយ្យាករណ៍វិស័យ"ខ្មែរ [ក់ណ-]/[ក់ន-] គួរយើងខំវិភាគសិក្សាឱ្យបានច្បាស់ ដើម្បីបានជាជំនួយដល់ការសិក្សាអំពីភាសាខ្មែរ) : តើ[ក់ន-] ក្នុង"កន្ទ្រង"ជាផ្នត់ដើមតែមួយ ដូចគ្នានឹង[ក់ន-] ក្នុង"កន្តឿ"ឬយ៉ាងណា?

ម្យ៉ាងទៀត ខ្ញុំសូមបញ្ជាក់ថា ខ្ញុំដាក់ "វេយ្យាករណ៍វិស័យ" ក្នុងអព្ភន្តរ ពីព្រោះជាពាក្យដែលខ្ញុំបានបង្កើតឡើងដោយយកលំនាំតាម "វត្ថុវិស័យ"(objectif), អត្តវិស័យ (subjectif) ហើយ ដែលគេមិនដែលស្គាល់។ ជាគោលការណ៍ នៅបស្ចិមប្រទេស គេតែងតែធ្វើបែបនេះសម្រាប់ néologismes ថ្មីៗ។ តាមរយៈពាក្យ "វេយ្យាករណ៍វិស័យ" ខ្ញុំចង់សងពាក្យបារាំង "grammatical" (ក្នុងករណីឯទៀត ការប្រើអព្ភន្តរមិនសូវសមស្របទេ បើប្រើអក្សរទ្រេត វាសមស្របជាង)។

(...)

(២៤) [-ប-] + កាច់ > ក្បាច់

(...)

(២៤ខ) [-ប-] + លើក > ល្បើក

(២៤គ) [-ប-] + លេង > ល្បែង

(២៤ឃ) [-ប-] + លួង > ល្បួង

(២៤ង) [-ប-] + លាយ > ល្បាយ

(...)

(២៥) [-ម-] + កាន់ > ខ្មាន់

(២៥ក) [-ម-] + ចាំ > ឆ្មាំ

(...)

### ៣.២.១.២.១. ផ្នត់ដើមទម្រង់ [ពស-]

(...)

(៣០ក) [ក-] + កាយ > កកាយ[២៧]

(...)

(៣១) [គ-] + គឹក > គគឹក

(...)

(៣២) [ង-] + ងក់ > ងងក់

(៣២ក) [ង-] + ងឹងងើ > ងងឹងងើ

(...)

(៣៣) [ញ-] + ញ័រ > ញញ័រ

(...)

(៣៣ខ) [ញ-] + ញើញ័រ > ញញើញញ័រ

(...)

(៣៤) [ច-] + ចឹក > ចចឹក

(...)

(៣៤ឃ) [ច-] + ចេចចាច > ចចេចចចាច

---

[២៧]: ព្យញ្ជនៈ"ក"ក្នុងពាក្យ"កកាយ", "គ"ក្នុងពាក្យ"គគឹក",... ជាបាតុភូតទ្វេនីយកម្មនៃព្យញ្ជនៈទី១របស់ពាក្យដើម("កាយ", "គឹក",...) ដែលឥតមានលក្ខណៈជាផ្នត់ទេ។

(...)

(៣៥) [ជ-] + ជុះ > ជជុះ

(...)

(៣៥ខ) [ជ-] + ជីក > ជជីក

(...)

(៣៥ង) [ដ-] + ដែល > ដដែល

(៣៥ង) [ដ-] + ដុស > ដដុស

(...)

(៣៦គ) [ត-] + តេះតះ > តតេះតតះ

(៣៦ឃ) [ត-] + តិបតុប > តតិបតតុប

(...)

(៣៧ក) [ទ-] + ទះ > ទទះ

(៣៧ខ) [ទ-] + ទាក់ > ទទាក់

(...)

(៣៨) [ប-] + បោស > បបោស

(...)

(៣៨គ) [ប-] + បេះបោច > បបេះបបោច

(...)

(៣៩ក) [ប៉-] + ប៉ប់ > ប៉ប៉ប់

(៣៩ខ) [ប៉-] + ប៉ាច់ > ប៉ប៉ាច់

(...)

(៤០ខ) [ព-] + ពួន > ពពួន

(៤០គ) [ព-] + ពួក > ពពួក

(...)

(៤១ក) [ម-] + មៃ > មមៃ

(...)

(៤១គ) [ម-] + មិងមាំង > មមិងមមាំង

(...)

(៤២ច) [រ-] + ងំ > រងំ

(...)

(៤២វ) [រ-] + បក > របក

(...)

(៤២វ) [រ-] + បើក > របើក

(...)

(៤២អ) [រ-] + បុក > របុក

(៤៣) [រ-] + បាំង > របាំង[២៨]

(...)

### ៣.២.១.២.២. ផ្នត់ដើមទម្រង់ [ពពស-]

ផ្នត់ដើមទម្រង់នេះពុំអនុញ្ញាតឱ្យសរសេរពាក្យកម្លាយតាមបែបតំរួតព្យាង្គឡើយ ទោះបីវាត្រូវបានកម្លាយចេញពីឫសដែលជាព្យាង្គតំរួតក៏ដោយចុះ។

(...)

(៤៥) [ក្រ-] + ម៉ាប់ > ក្រមាប់

(...)

(៤៥ខ) [ក្រ-] + វិល > ក្រវិល

(...)

(៤៦) [គ្រ-] + វាត់ > គ្រវាត់

(...)

(៤៦គ) [គ្រ-] + វែង > គ្រវែង

(...)

(៤៧) [ច្រ-] + ងក់ > ច្រងក់

(៤៧ក) [ច្រ-] + បាច់ > ច្របាច់

(...)

(៤៩) [ត្រ-] + បក > ត្របក

(៤៩ក) [ត្រ-] + សង > ត្រសង

(...)[២៩]»

---

[២៨] : ផ្នត់ដើម[រ-]ជាសទិសសូរ"វេយ្យាករណ៍វិស័យ"(homonymie grammaticale) រវាងផ្នត់ដើមជាច្រើន, ឧទាហរណ៍ :

- [រ-] + បើក > របើក "បើក"ជាកិរិយាសព្ទសកម្ម, "របើក" គឺបើកដោយខ្លួនឯង គឺជា"កិរិយាសព្ទអកម្ម"ឬ"កិរិយាសព្ទអត្តផល"
- [រ-] + បុក > របុក (របុកជាឧទាហរណ៍សម្រាប់បុក)។ល។

ដូចផ្នត់ដើម[ក´ណ-]/[ក´ន-]ដែរ ផ្នត់ដើម[រ-]ត្រូវការការវិភាគសិក្សាឱ្យបានស៊ីជម្រៅដើម្បីបានជាជំនួយដល់ការសិក្សាអំពីភាសាខ្មែរ។

### VII.២.៣- <u>សេចក្ដីសន្និដ្ឋានលើទស្សនៈរបស់អ្នកនិពន្ធ“សំណោរនិងអក្ខរាវិរុទ្ធខ្មែរ”</u>

**ខ្ញុំឥតបានស្រង់ចំណុចទាំងអស់ទាក់ទងនឹងព្យាង្គរាយនិងព្យាង្គតម្រួតដែលមានក្នុងស្នាដៃខាងលើនេះទេ។ ខ្ញុំស្រង់តែចំណុចមួយចំនួនដែលគ្រប់គ្រាន់សម្រាប់ខ្ញុំ ដើម្បីសន្និដ្ឋានថា គោលការណ៍អាស្រ័យផ្នត់របស់អ្នកនិពន្ធ “សំណោរនិងអក្ខរាវិរុទ្ធខ្មែរ” ឥតមានលក្ខណៈសកលដូចគោលការណ៍អាស្រ័យឫសរបស់សម្ដេច ជួន ណាត ដែរ។**

**សូមសាធារណជនអានឡើងវិញនូវ :**

(១)- <u>ចំណុច៣.២.១.១.១.ទាក់ទងនឹងផ្នត់ដើមទម្រង់ [ព-] និង ឧទាហរណ៍មួយចំនួន ដូចខាងក្រោម</u> :

«ជាទូទៅ ផ្នត់ដើមទម្រង់ [ព-] នេះប្រើផ្សំនឹងឫសដែលសុទ្ធសឹងតែជាពាក្យសរសេរជាព្យាង្គរាយ ហើយវាតម្រូវឱ្យសរសេរពាក្យកម្លាយជាព្យាង្គតំរួតទាំងអស់។ (...)។ ឧទាហរណ៍ :

(១) [ក-] + បាំង > ក្បាំង

(...)

(២) [ច-] + បួត > ច្បួត

(...)

(៣) [ត-] + បារ > ត្បារ

(...)

(៤) [ប-] + ដាច់ > ផ្ដាច់

(...)»

<u>និង</u>

(២)- <u>ចំណុច៣.២.១.១.២.ទាក់ទងនឹងផ្នត់ដើមទម្រង់ [ពសព-] និង ឧទាហរណ៍មួយចំនួនដែរ ដូចខាងក្រោម</u> :

«ផ្នត់ដើមទម្រង់ [ពសព-] ទាំងអស់សុទ្ធតែកម្លាយពាក្យឫសឱ្យបានទៅជាពាក្យដែលសរសេរជាតំរួតព្យាង្គទាំងអស់ ទោះបីពាក្យឫសនោះជាព្យាង្គរាយឬជាព្យាង្គតំរួតក៏ដោយ។ ចំពោះពាក្យកម្លាយតាមរយៈផ្នត់ដែលមានសូរ |អ´ម| ដូចជា |ក´ម| |ដ´ម|។ល។ គឺត្រូវសរសេរជារាយព្យាង្គ ប្រសិនបើគេកត់ត្រាសូរ |អ´ម| នោះដោយសញ្ញាដំលើ។

(៧) [ច´ង-] + គ្រោង > ចង្គ្រោង

(៧ក) [ច´ង-] + អួរ > ចង្អួរ

(...)

---

២៩ : ច័ន្ទ សំណព្វ “សំណោរនិងអក្ខរាវិរុទ្ធខ្មែរ” រោងពុម្ពហ្គូណាន, ឆ្នាំ២០០៨ (ស្រង់ចេញពីទំព័រ៨៦ដល់ទំព័រ១០៨)។

(៨ក) [ដ´ង-] + ហក់ > ដង្ហក់

(៨ខ) [ដ´ង-] + ហែ > ដង្ហែ

(...)

(៩) [ប´ង-] + ក > បង្ក

(៩ក) [ប´ង-] + កើត > បង្កើត

(...)»

សាធារណជនអាចឃើញថា ពាក្យ“ក្បាំង”, “ច្បូត”,... ដែលជាពាក្យឯកព្យាង្គ ហើយ ដែលយើងទាំងអស់គ្នា ក៏ដូចសម្តេច ជួន ណាត ដែរ ហៅថា ពាក្យឯកព្យាង្គសរសេរនឹងអក្សរតម្រួតឬផ្ញើជើង ត្រូវបានអ្នកនិពន្ធ “សំណេរនិងអក្ខរាវិរុទ្ធខ្មែរ” ហៅថា “ព្យាង្គតំរួត” ដូចគ្នានិងពាក្យ “ចង្វារ”, “បង្កើត”,...ដែរ ដែលជាព្យាង្គតម្រួតពិតប្រាកដមែន។

សូវវិទូប្រកបដោយវិចារណញ្ញាណណាក៏មិនអាចចាត់ទុកពាក្យ“ក្បាំង”ឬ“ច្បូត”ថា  ជាពាក្យពីរព្យាង្គឡើយ (ដូច ពាក្យបារាំង trop ឬ stade និង ពាក្យអង់គ្លេស speak ឬ bring ជាដើមដែរ)។ គេតែងតែហៅពាក្យខ្មែរទាំងនេះ(“ក្បាំង”,  “ច្បូត”,...)ថាជាពាក្យឯកព្យាង្គសរសេរនឹងអក្សរតម្រួតឬផ្ញើជើង។  គេនឹងអាចហៅថាជា“ព្យាង្គតម្រួត” លុះណាមានព្យាង្គពីរសម្រាប់ដាក់ព្យាង្គមួយលើព្យាង្គមួយទៀត។ អ្នកនិពន្ធ “សំណេរនិងអក្ខរាវិរុទ្ធខ្មែរ” បានច្រឡំអក្សរតម្រួតនិងព្យាង្គតម្រួត។

អ្នកនិពន្ធអាចឆ្លើយថា គាត់ឥតបានច្រឡំទេ។ គាត់បានចាត់ទុកពាក្យ“ក្បាំង”, “ច្បូត” ជាដើម ថាជា“ព្យាង្គតំរួត” ដោយសំអាងលើនិយមន័យរបស់គាត់។ ប៉ុន្តែ យើងអាចសួរទៅវិញថា : “តើភាសាវិទ្យាជាវិជ្ជាដែលអនុញ្ញាតឱ្យអ្នកស្រាវជ្រាវកាឡៃន័យនៃពាក្យដែលគេធ្លាប់ស្គាល់គ្រប់គ្នា តាមតែគាត់ចង់បាន ដើម្បី“វាយភាសាបញ្ចូលក្នុងទ្រឹស្តី ឬ?”។

## VIII. <u>សំណើ[៣០] រៀបចំកម្ទេចពាក្យ[៣១] តាមក្រុម ដើម្បីចៀសភាពរប៉ាត់រប៉ាយ</u>

[៣០] ក្នុងវចនានុក្រមពាក្យ “សំណើ” មិនមែនជាពាក្យកើតចេញពីកិរិយាសព្ទ “ស្នើ” ទេ  ប៉ុន្តែ ខ្ញុំប្រើតាមទម្លាប់ខុសសិនចុះទម្រាំ ក.ជ.ភ.ខ. មានឱកាសពិគ្រោះនិងសម្រេចបែបណា។។

[៣១] បញ្ញត្តិ “កម្ទេចពាក្យ” ខ្ចីពីលោក អៀវ កើស (គាត់ហៅ “កន្ទេចពាក្យ”) ដែលគាត់បានប្រើក្នុងសៀវភៅរបស់គាត់ឈ្មោះ “ភាសាខ្មែរ”, បណ្ណាគារមិត្តសេរី, ឆ្នាំ១៩៦៧, ទំព័រ១៦៨។ តាមរយៈពាក្យនេះ ដែលមានន័យប្រហាក់ប្រហែល (គ្រាន់តែប្រហាក់ប្រហែលទេ) នឹង រូបតា គាត់ចង់សម្គាល់ធាតុដែលមិនឯករាជ្យ ហើយ ដែលគេប្រើសម្រាប់កម្លាយពាក្យ។

ខ្ញុំសូមរំលឹកឡើងវិញថា រូបតានៃភាសាខ្មែរមានសទិសសូរ“វេយ្យាករណ៍វិស័យ” (homonymie grammaticale) ជាច្រើន។ តាមនិក្ខេបបទរបស់លោកបណ្ឌិត វង្ស ម៉េង ផ្នត់មួយមានន័យជាច្រើន។ ដូច្នេះ វាក៏អាចមានប្រភេទជាច្រើនដែរ។ ប៉ុន្តែ ខ្ញុំនឹងលើកយកមកនិយាយក្នុងសិក្សាកថាខ្ញុំនេះ តែកម្ទេចពាក្យសំខាន់ៗទេ។

តាមវិភាគរបស់ខ្ញុំ និង ដោយផ្អែកលើទស្សនៈរបស់អ្នកស្រាវជ្រាវជំនាន់មុនខ្លះផង ខ្ញុំបានសង្កេតឃើញថា អ្វីដែលគេហៅថា “ផ្នត់” អាចចែកជាបីក្រុម[៣២]។

## VIII.១- **ផ្នត់ (ឬ អញ្ញាសបទ)**

ផ្នត់ជារូបតា ដែលមានរូបនិងន័យស្ថុលនឹងនរ លើកលែងតែមានកាឡារូបនិងការល្អៀងន័យតាមរយៈកាល។ គេអាចប្រើផ្នត់សម្រាប់បង្កើតពាក្យថ្មីៗជាច្រើនឥតគណនា ដោយយកលំនាំតាមពាក្យដែលមានស្រាប់។

### VIII.១.១- ***រូបតាជែក /-អ´ម-/ & /-អ៊ិ´ម-/ និង កាឡារូបរបស់វា ដែលទាក់ទងនឹងព្យាង្គតម្រួតរបស់សម្ដេច ជួន ណាត***

ករណីនេះ ខ្ញុំបានបង្ហាញម្ដងហើយ នៅពេលដែលខ្ញុំនិយាយពីពាក្យកម្លាយកើតចេញពីពាក្យសរសេរនឹងអក្សរតម្រួតឬផ្ញើជើង របស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត**។ ខ្ញុំសុំអនុញ្ញាតលើកវាមកបង្ហាញម្ដងទៀត ដើម្បីឱ្យវានៅជុំគ្នាជាមួយនឹងក្រុមវា។ នេះជារូបតាជែក /-អ´ម-/ & /-អ៊ិ´ម-/ និង កាឡារូបរបស់វា ៖

- [-អ´ង-]/[-អ៊ិ´ង-], ឧ. ខ្វល់ + [-អ´ង-] > កង្វល់;
- [-អ´ញ- ]/ [-អ៊ិ´ញ-], ឧ. ខ្ចប់ + [-អ´ញ- ] > កញ្ចប់;
- [-អ´ណ-]/ [-អ៊ិ´ណ-], ឧ. ប្ដឹង + [-អ´ណ-] > បណ្ដឹង;
- [-អ´ន-]/[-អ៊ិ´ន-], ឧ. ភ្លឹក + [-អ៊ិ´ន-] > ពន្លឹក;
- [-អ´ម-]/[-អ៊ិ´ម-], ឧ. គ្រប + [-អ៊ិ´ម-] > គម្រប, ខ្ចាត់ + [-អ´ម-] > កម្ចាត់។

### VIII.១.២- ***រូបតាជែក /-អ´ម-/ & /-អ៊ិ´ម-/ និង កាឡារូបរបស់វា សម្រាប់បង្កើតពាក្យសម្គាល់ឧបករណ៍***[៣៣]

- [-អ´ម-]/[-អ៊ិ´ម-], ឧ. ច្រូង + [-អ´ម-] > ចម្រូង,
- [-អ´ន-]/[-អ៊ិ´ន-], ឧ. ក្ដាស់ + [-អ´ន-] > កន្ដាស់។

### VIII.១.៣- ***រូបតាផ្នត់ដើម /អ´ន-/ & /អ៊ិ´ន-/ និង កាឡារូបរបស់វា សម្រាប់បង្កើតពាក្យសម្គាល់ឧបករណ៍***

- [អ´ន-]/[អ៊ិ´ន-], ឧ. ទាក់ + [អ´ន-] > អន្ទាក់,

---

[៣២] : ខ្ញុំបានប្រើពាក្យ “កម្ទេចពាក្យ” ពីព្រោះផ្នត់គ្រាន់តែធាតុមួយក្រុមក្នុងចំណោមកម្ទេចពាក្យឯទៀត។

[៣៣] : រូបតាក្នុងចំណុច VIII.១.២-នេះ ជាសទិសសូរ “វេយ្យាករណ៍វិស័យ” ជាមួយរូបតានៃចំណុច VIII.១.១- ខាងលើ។

- [អ´ញ-]/[អ៊ិ´ញ-], ឧ. ជុល + [អ´ញ-] > អញ្ចុល,
- [អ´ង-]/[អ៊ិ´ង-], ឧ. រុត + [អ´ង-] > អង្រុត។

### VIII.១.៤- រូបតាផ្នត់ដើម /ក-/ & /គ-/ និង កាឡូរូបរបស់វា ដែលគេប្រើសម្រាប់បង្អាប់

សម្រង់របស់ក្រុមយើង[៣៤]បានប្រទះ /ក-/ ផង /គ-/ ផង /ក´ញ-/ ផង /កន-/ ផង, ... , ឧទាហរណ៍ ៖

- [ក-]/[គ-], ឧ. ឌី + [គ-] > គ្ឌី,
- [ក-]/[គ-], ឧ. មុំ + [ក-] > ក្មុំ > ខ្ញុំ,
- [ក-]/[គ-], ឧ. បាក់ + [ក-] > កបាក់,
- [ក´ញ-]/[គ´ញ-], ឧ. ចាស់ + [ក´ញ-] > កញ្ចាស់,
- [ក´ន-]/[គ´ន-], ឧ. តឿ + [ក´ន-] > កន្តឿ។

<u>កំណត់សម្គាល់</u> ៖

(១) រូបផ្សេងៗនៅក្នុងពាក្យ "ខ្ញុំ", "គ្ឌី", "កបាក់", "កញ្ចាស់", "កន្តឿ" ពិតជាកាឡូរូបរបស់រូបតា /ក-/ & /គ-/ មែន ពីព្រោះ កាលណាគេនិយាយ គេថា "អាក្តឿ", "អាក្ចាស់", ... អក្ខរាវិរុទ្ធ "កន្តឿ", "កញ្ចាស់" គ្រាន់តែជាការសម្រេចរបស់អក្ខរាវិរុទ្ធករមួយក្រុមដែលបានក្លាយទៅជាទម្លាប់ (ដែលយើងត្រូវតែគោរព)។

(២) ខ្ញុំខ្វះពេលដើម្បីប្រមូលផ្ដុំកាឡូរូបជុំវិញរូបតានីមួយៗនៃភាសាខ្មែរ (ដោយមិនត្រូវភ្លេចសទិសសូរ"វេយ្យាករណ៍វិស័យ" ផង)។ ខ្ញុំសូមស្លេះការវិភាគរបស់ខ្ញុំតែត្រឹមនេះ។ បើអ្នកស្រាវជ្រាវណាយល់ថាមាគ៌ានេះជាមាគ៌ាសមស្រប សូមលោកបន្តការវិភាគបែបនេះតទៅទៀត ឱ្យបានសព្វគ្រប់ និង ឱ្យបានស៊ីជម្រៅ។

## VIII.២- <u>បឋមឫស</u>

លោក Joseph Guesdon បានរៀបរៀងវចនានុក្រមមួយ ព្រមទាំងកូនសៀវភៅវេយ្យាករណ៍ឧបសម្ព័ន្ធមួយផង ដែលក្នុងនោះគាត់បានលើកឡើងអំពី racines primaires[៣៥] ដែលយើងប្រែថា "បឋមឫស"។ បឋមឫសជាសំណល់នៃផ្នត់ដែលបានចុះថយពីការប្រើប្រាស់ដើម្បីបង្កើតពាក្យ។ បឋមឫសមានលក្ខណៈប្រហាក់ប្រហែលនឹងផ្នត់ដែរ ប៉ុន្តែ គេមិនអាចយកវាទៅបង្កើតពាក្យថ្មីឱ្យបានទូលំទូលាយដូចផ្នត់ទេ, ឧទាហរណ៍ ៖

- បឋមឫស /ក-/ + បាំង > ក្បាំង (បឋមឫស /ក-/ ហាក់ដូចជាមិនអាចប្រើជាមួយកិរិយាសព្ទទូទៅសម្រាប់បង្កើតពាក្យសម្គាល់ឧបករណ៍ទេ[៣៦])។

---

[៣៤] *វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប*, ភាគទី២, រៀបរៀងដោយអ្នកស្រាវជ្រាវមួយក្រុម ក្រោមការទទួលខុសត្រូវរបស់បណ្ឌិត ព្រុំ ម៉ល់, ផ្សាយចេញនៅឆ្នាំ២០០៦, ទំព័រ២៦។

[៣៥] Joseph Guesdon, *Dictionnaire cambodgien-français*, Librairie Plon, Paris 1930.

[៣៦] ផ្នត់ដែលបានចុះឥទ្ធិពលនិងដែលបានក្លាយទៅជាបឋមឫសប្រាកដជាមាន ប៉ុន្តែ ដោយខ្ញុំមិនទាន់បានសិក្សាឱ្យបានសព្វគ្រប់ ឧទាហរណ៍របស់ខ្ញុំអាចខុស។ម្យ៉ាងទៀត គួររំលឹកថា កុំតែមានអន្តរាគមន៍ពីខេមរយានកម្ម ផ្នត់មួយចំនួនដូច /-ន-/, /-ម-/, /-amn-/, /-ɔmn-/,... ដែលនៅរស់និងកំពុងមានឥទ្ធិពលខ្លាំងសព្វថ្ងៃនេះ ប្រហែលជាត្រូវចុះថយដូចបឋមឫសដែរ ពីព្រោះ នៅពេលមួយនោះ គេនិយមប្រើ "ការ-", "សេចក្ដី-", "អ្នក-", "ប្រដាប់-", "ឧបករណ៍-", ... ក្នុងការបង្កើតពាក្យ។ ផ្នត់ "ព្យាបាល" ដោយខេមរយានកម្ម ត្រូវគេប្រើប្រាស់ជាញឹកញាប់ ហើយ ថែមទាំងបានដណ្ដើមយកពាក្យមួយចំនួនឱ្យចូលក្រោមឥទ្ធិពលរបស់ខ្លួន, ឧ. សេចក្ដីរាយការណ៍ > របាយការណ៍, ការដោះស្រាយ > ដំណោះស្រាយ ។ល។

- បឋមឫស /-ប-/ + ចារ > ច្បារ[៣៧] ។

## VIII.៣- **<u>ទ្វេនីយកម្មនៃព្យញ្ជនៈទី១នៃពាក្យណាមួយ ជាពិសេស កិរិយាសព្ទ ដើម្បីសម្គាល់អំពើផ្ទួន</u>**[៣៨]

ភាសាខ្មែរមានទ្វេនីយកម្មនៃព្យញ្ជនៈទី១នៃពាក្យដែលគេចង់ឱ្យមានអំពើផ្ទួន។ ពីព្រោះពាក្យជំពូកនេះអាចកើតពីព្យញ្ជនៈទាំង៣៣តួ ហើយ ដោយព្យញ្ជនៈនីមួយៗអាចបង្កើតពាក្យជាច្រើន ទ្វេនីយកម្មអាចនាំមកនូវព្យញ្ជនៈផ្ទួនចំនួនច្រើនរយ ៖ ដូច្នេះ គប្បីយើងគ្រាន់តែពន្យល់យន្តការនិងឱ្យឧទាហរណ៍មួយចំនួនបានហើយ ដើម្បីកុំឱ្យគេធុញទ្រាន់។

ម្យ៉ាងទៀត ទ្វេនីយកម្មនៃព្យញ្ជនៈទី១នៃពាក្យដែលគេចង់ឱ្យមានអំពើផ្ទួន ឥតមានលក្ខណៈជាផ្នត់ទេ ពីព្រោះព្យញ្ជនៈដែលទទួលទ្វេនីយកម្មនូវ៣៣ដង ស្របគ្នានឹងពាក្យខ្មែរដែលអាចកើតចេញពីព្យញ្ជនៈទាំង៣៣តួនៃអក្ខរក្រមខ្មែរ។ (សូមអាននិយមន័យរបស់ផ្នត់)។

## IX. **<u>យោបល់សរុប</u>**

ក្រោយពីបានរៀបរៀងសិក្ខាកថានេះចប់ហើយ ខ្ញុំបានសង្កេតឃើញថានៅក្នុងភាសាខ្មែរមានបញ្ហាជាច្រើនដែលយើងមិនទាន់យល់អស់ឬមិនទាន់យល់ដូចគ្នា ជាពិសេស បញ្ហាកម្មេចពាក្យឬរូបតា ដែលខ្ញុំយល់ថាមានដល់ទៅបីប្រភេទ, ដែលអ្នកស្រាវជ្រាវខ្លះយល់ថាមានពីរប្រភេទ, ដែលអ្នកស្រាវជ្រាវខ្លះទៀតយល់ថាមានតែមួយប្រភេទទេ ហើយ ដែលគេប្រើពាក្យ“ផ្នត់” ដើម្បីសម្គាល់វារួមគ្នា។ ភាគខាងចុងនៃសិក្ខាកថារបស់ខ្ញុំត្រូវបានសិក្សាជាត្រួសៗ ពីព្រោះខ្ញុំឥតមានពេលគ្រប់គ្រាន់(ខ្ញុំត្រូវបញ្ចប់អត្ថបទតាមកាលកំណត់)។ ប៉ុន្តែ ខ្ញុំបានខំប្រមូលផ្តុំរូបតាជាក្រុម ដើម្បីចៀសភាពរប៉ាត់រប៉ាយ។ ខ្ញុំសង្ឃឹមថា ការប្រមូលផ្តុំនេះអាចជួយអ្នកប្រើប្រាស់ភាសាខ្មែរឱ្យងាយយល់អំពីបញ្ហានេះ។

X X

X

---

[៣៧] : បឋមឫស /-ប-/ នេះ, ដើមចមនៃពាក្យ “ច្បារ” (ទីដាំបន្លែ (...) ដែលមានចំណារដោយឡែក) អាចជាសទិសសូរ “វេយ្យាករណ៍វិស័យ” ជាមួយនឹងផ្នត់ /-ប-/ សម្រាប់ប្រើក្នុងការបង្កើតពាក្យសម្គាល់លទ្ធផលដែលកម្លាយចេញពីពាក្យដើមសរសេរនឹង “យ”, “រ”, “ល”, ឧ. យល់ > យោបល់, រៀប > របៀប, លាយ > ល្បាយ,...។

[៣៨] : លើកលែងតែក្នុងករណីខ្លះដែលពាក្យត្រូវបានល្អៀងន័យក្នុងបរិបទពិសេស ឬ ក្រោមឥទ្ធិពលនៃបរិបទនិង/ឬនៃរយៈកាល (diachronie)។

# <u>គន្ថនិទ្ទេសសង្ខេប</u>

**១. <u>ជាភាសាខ្មែរ</u> :**

- ច័ន្ទ សំណព្វ, *សំណេរនិងអក្ខរាវិរុទ្ធខ្មែរ,* រាជបណ្ឌិតសភាកម្ពុជា, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ភ្នំពេញ, ២០០៨ ;
- ជួន ណាត (ក្រោមការដឹកនាំ), វចនានុក្រមខ្មែរ ភាគ១ & ២, ពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពគ្រាទី៥, ១៩៦៧ & ១៩៦៨ ;
- ព្រុំ ម៉ល់, *អំពីសញ្ញាប្រយោគចម្រូងចម្រាសមួយចំនួន ក្នុងភាសាខ្មែរបច្ចុប្បន្ន,* ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, មេសា ២០១២ ;
- ព្រុំ ម៉ល់ (ក្រោមការដឹកនាំ), *វេយ្យាករណ៍ទម្រង់និយម នៃភាសាខ្មែរទំនើប,* ភាគទី២ (ការបង្កើតពាក្យ), ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, សីហា ២០០៦ ;
- ព្រុំ ម៉ល់ (ក្រោមការដឹកនាំ), *វេយ្យាករណ៍ទម្រង់និយម នៃភាសាខ្មែរទំនើប,* ភាគទី១ (សូរ សទ្ទតា និង អក្ខរាវិរុទ្ធ), ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ឆមាសទី១ ២០០៦ ;
- ព្រុំ ម៉ល់, *មូលដ្ឋាននៃ សូរវិទ្យា សទ្ទតាវិទ្យា & វិជ្ជាសន្ទាន,* ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ខែកក្កដា ២០០៣ ;
- អៀវ កើស, *ភាសាខ្មែរ : សាកល្បងពិនិត្យដោយរកហេតុផល,* បណ្ណាគារ មិត្តសេរី, ភ្នំពេញ, ១៩៦៧ ;

**២- <u>ជាភាសាបារាំង</u> :**

- Dubois Jean *et al, Dictionnaire linguistique,* Larousse, Paris, 1973 ;
- Guesdon Joseph, *Dictionnaire cambodgien-français,* 2 tomes, Libraire PLON, Paris, 1930 ;
- Saussure Ferdinand de, *Cours de linguistique générale,* Payot, Paris, 1960 ;

X X

X